សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Science Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# តួនាទី និងភារកិច្ច
# នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ ភិក្ខុ **ខុនលី ឌីណា**
លោក **សៀង ម៉ុនលី**

សាស្ត្រាចារ្យណែនាំ
លោក **ញឹក ខុឌ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

អាត្មាភាពខ្ញុំបាទឈ្មោះ **វុនលី ឌីណា** និង **សៀង ប៊ុនលី** ជានិស្សិតបង់ថ្លៃ ថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត ជំនាញនីតិសាស្រ្ត ជំនាន់ទី ១៩ ក្រុម L4C1 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាល័យសេដ្ឋកិច្ច។

**សូមថ្លែងអំណរគុណ និងសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅចំពោះ**

ញោមប្រុស **សោម វុនលី** និងញោមស្រី **ព្រំ ណាប់** ដែលជាអ្នកមានគុណរបស់អាត្មាភាព **វុនលី ឌីណា** និងលោកឪពុក **សៀង ស៊ូរ** និងអ្នកម្តាយ **យូ ភាង** ដែលជាឪពុកម្តាយរបស់ខ្ញុំបាទ **សៀង ប៊ុនលី** ដែលលោកទាំងពីរជាអ្នកមានគុណូបការៈយ៉ាងធំធេងចំពោះរូបកូន ដោយគុណមួយនេះមិនអាចកាត់ថ្លៃបាន និងរកអ្វីមួយមកប្រៀបផ្ទឹមពុំបានឡើយ។

អាត្មាភាពខ្ញុំបាទសូមគោរពថ្លែងអំណរគុណផងដែរចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក និងលោកស្រីសាស្រ្តាចារ្យ និងមន្រ្តីបុគ្គលិក ការិយាល័យសិក្សា និងបណ្ណារ័ក្ស** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាល័យសេដ្ឋកិច្ច ដែលបានខិតខំទាំងកម្លាំងកាយចិត្តក្នុងការដឹកនាំ គ្រប់គ្រង ជួយជ្រោមជ្រែងគ្រប់បែបយ៉ាង និងជួយបង្ហាត់បង្រៀនដល់យើងខ្ញុំទាំងពីរនាក់ឱ្យមានចំណេះដឹងដើម្បីសម្រាប់ប្រើប្រាស់ក្នុងការដោះស្រាយជីវភាពរស់នៅប្រចាំថ្ងៃ និងសង្គមជាតិផងដែរ។

អាត្មាភាពខ្ញុំបាទទាំងពីរនាក់ ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតគោរពជូនចំពោះ លោកសាស្រ្តាចារ្យ **ញឹក វុធ្ធី** ដែលលោកបានបង្ហាត់បង្រៀនអាត្មាភាពខ្ញុំបាទទាំងពីរយ៉ាងយកចិត្តទុកដាក់ មិនត្រឹមតែប៉ុណ្ណោះទេ លោកថែមទាំងបានចំណាយពេលដ៏មមាញឹកនិងមានតម្លៃបំផុត តែងតែជួយណែនាំក្នុងការសរសេរសារណានេះឱ្យបានសម្រេចជាផ្លែផ្កា។

ជាចុងក្រោយ អាត្មាភាពខ្ញុំបាទទាំងពីរនាក់សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធទាំងអស់ក្នុងលោក សូមជួយតាមបីបាច់ថែរក្សា ការពារដល់លោកឪពុក អ្នកម្តាយ និងអ្នកមានគុណទាំងអស់ ឱ្យជួបប្រទះតែសេចក្តីសុខសេចក្តីចម្រើន មានសុភមង្គល អាយុយឺនយូរ បញ្ញាញាណវាងវៃ និងប្រកបដោយពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាបឋមអាត្មាភាពខ្ញុំបាទទាំងពីរនាក់ សូមធ្វើការបង្ហាញនូវសេចក្តីសោមនស្សយ៉ាងខ្លាំង និងស្វាគមន៍យ៉ាងកក់ក្តៅពីសំណាក់ លោក លោកស្រី សាស្ត្រាចារ្យ សិស្ស និស្សិត និងមិត្តអ្នកអានទាំងអស់ ដែលបានផ្តល់កិត្តិយសក្នុងការអានសៀវភៅរបស់អាត្មាភាពខ្ញុំបាទ ដែលបានសរសេររាប់រៀបអំពី **"តួនាទី និងភារកិច្ចរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម"**។ អាត្មាភាពខ្ញុំបាទទាំងពីរនាក់មានសេចក្តីរីករាយយ៉ាងពន់ពេកណាស់ ចំពោះការផ្តល់ឱកាសពីសំណាក់សាកលវិទ្យាល័យ ក្នុងការអនុញ្ញាតអោយអាត្មាភាពខ្ញុំបាទ ធ្វើការបញ្ចេញនូវសមត្ថភាពរបស់ខ្លួន បន្ទាប់ពីធ្វើការសិក្សាអស់រយៈពេល ៤ ឆ្នាំកន្លងមក តាមរយៈការសរសេរសារណាស្រាវជ្រាវមួយនេះ ដើម្បីបញ្ចប់នូវថ្នាក់បរិញ្ញាបត្ររបស់ខ្លួន។ នេះគឺជាសមទ្ធិផលមួយដែលកើតឡើងពីការខិតខំប្រឹងប្រែង ព្យាយាមក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដើម្បីបន្សល់ទុកជាស្នាដៃមួយមុន នឹងឈានជើងចាកចេញពីសាកលវិទ្យាល័យនាពេលខាងមុខនេះ និងដើម្បីជាគុណប្រយោជន៍សម្រាប់សិស្ស និស្សិតជំនាន់ក្រោយៗ ក្នុងការសិក្សាស្រាវជ្រាវបន្ត។

ការសិក្សាអស់រយៈពេលបួនឆ្នាំកន្លងមកនេះ គ្រប់មុខវិជ្ជាដែលអាត្មាភាពខ្ញុំបាទបានរៀន គឺសុទ្ធតែជាមុខវិជ្ជាដែលសំខាន់ៗសម្រាប់អនុវត្តក្នុងសង្គមជាតិនាពេលបច្ចុប្បន្ននេះ ហើយសម្រាប់អាត្មាភាពខ្ញុំបាទផ្ទាល់ដោយយល់ឃើញថា ព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃ ជាប្រទេសដែលកំពុងអភិវឌ្ឍន៍ ទើបបណ្តាលឲ្យមានការផ្តោតអារម្មណ៍យ៉ាងខ្លាំងទៅលើមុខវិជ្ជានីតិកម្មសិទ្ធិបញ្ញា។ កម្មសិទ្ធិបញ្ញាជាឧបករណ៍មួយដ៏សំខាន់ សម្រាប់ពង្រីកវិស័យពាណិជ្ជកម្ម និងទាក់ទាញវិនិយោគជាតិ និងអន្តរជាតិ។ កម្មសិទ្ធិបញ្ញាគឺទាក់ទងទៅនឹងមូលហេតុចំបងពីរគឺៈ ទី១. បុគ្គលមួយចំនួនបានខិតខំប្រឹងព្យាយាម ក្នុងការបង្កើតគំនិតថ្មី និងអនុវត្តគំនិតនោះដើម្បីបង្កើតជាស្នាដៃ ដែលអាចទទួលបាននូវផលប្រយោជន៍ពីលទ្ធផលនៃគំនិតរបស់ខ្លួន។ ទី២. នៅពេលបុគ្គលដែលបានបង្កើតស្នាដៃចេញពីគំនិតប្រាជ្ញារបស់របស់ខ្លួនរួច ហើយត្រូវទទួលសិទ្ធិការពារលើការខិតខំ ប្រឹងប្រែងផ្នែកប្រាជ្ញារបស់គាត់ បើមិនដូច្នោះទេ នឹងមានការរំលោភបំពានទៅលើស្នាដៃនោះជាក់ជាមិនខាន។

ទោះបីជាយ៉ាងណាក៏ដោយ អាត្មាភាពខ្ញុំបាទក៏សូមធ្វើការខន្តី អភ័យទោសនូវរាល់ចំណុចខ្វះខាត ដូចជាពាក្យពេចន៍ អត្ថន័យ ឬកំហុសឆ្គងអចេតនាណាមួយដែលមាននៅក្នុងសារណាមួយនេះទុកជាមុន ព្រោះយើងខ្ញុំជឿជាក់ថា ពិតជាគ្មានអ្វីដែលអាចល្អឥតខ្ចោះបាននោះឡើយ ដូចនេះអាត្មាភាពខ្ញុំបាទត្រូវតែទទួលស្គាល់នូវកំហុស និងទទួលយកនូវការកែតម្រូវតាមរយៈការផ្តល់ជាមតិយោបល់ រិះគន់ដើម្បីស្ថាបនារបស់មិត្ត និស្សិត អ្នកអានទាំងអស់ ដើម្បីឲ្យស្នាដៃមួយនេះកាន់តែមានភាពល្អប្រសើរឡើង។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃកម្មសិទ្ធិបញ្ញា**

**ផ្នែកទី១៖ ប្រវត្តិនៃកម្មសិទ្ធិបញ្ញានៅព្រះរាជាណាចក្រកម្ពុជា** ........................................ ៤

**កថាភាគទី១៖ សាវតា** ........................................ ៤

**កថាភាគទី២៖ ស្ថាបនិក** ........................................ ៤

**កថាភាគទី៣៖ គណៈកម្មាធិការគ្រប់គ្រងផ្នែកទាំងបីនៃកម្មសិទ្ធិបញ្ញា** ........................................ ៦

**កថាភាគទី៤៖ គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា** ........................................ ៧

**កថាភាគទី៥៖ ក្របខណ្ឌច្បាប់** ........................................ ៧

**ផ្នែកទី២៖ ក្រសួងជំនាញកម្មសិទ្ធិបញ្ញា** ........................................ ៩

**កថាភាគទី១៖ ក្រសួងពាណិជ្ជកម្ម** ........................................ ៩

១. នាយកដ្ឋានកម្មសិទ្ធិបញ្ញា ........................................ ១០

២. ការរៀបចំច្បាប់ និងបទប្បញ្ញត្តិ ........................................ ១១

៣. ការងារបណ្តុះបណ្តាល ........................................ ១៣

៤. ការងារចុះបញ្ជី ........................................ ១៤

**កថាភាគទី២៖ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម** ........................................ ១៤

១. នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ........................................ ១៥

២. ការរៀបចំច្បាប់ និងបទប្បញ្ញត្តិ ........................................ ១៥

៣. ការងារបណ្តុះបណ្តាល ........................................ ១៦

៤. ការងារចុះបញ្ជី ........................................ ១៧

**កថាភាគទី៣៖ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** ........................................ ១៨

១. នាយកដ្ឋានកម្មសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ........................................ ១៨

២. ការរៀបចំច្បាប់ និងបទប្បញ្ញត្តិ ........................................ ១៩

៣. ការងារបណ្តុះបណ្តាល ..................... ១៩
៤. ការងារចុះបញ្ជី ..................... ២១

## ជំពូកទី២

## រចនាសម្ព័ន្ធ និងតួនាទីភារកិច្ច

**ផ្នែកទី១៖ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម** ..................... ២២
**កថាភាគទី១៖ ការរៀបចំរចនាសម្ព័ន្ធ** ..................... ២២
**កថាភាគទី២៖ តួនាទី និងភារកិច្ចរបស់ការិយាល័យនីមួយៗ** ..................... ២៣
១. ការិយាល័យចុះបញ្ជីម៉ាកពាណិជ្ជកម្ម ..................... ២៣
២. ការិយាល័យចុះបញ្ជីម៉ាកអន្តរជាតិ ..................... ២៤
៣. ការិយាល័យក្រោយចុះបញ្ជីម៉ាកពាណិជ្ជកម្ម ..................... ២៤
៤. ការិយាល័យម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ និងព័ត៌មានសម្ងាត់ពាណិជ្ជកម្ម ..................... ២៥
៥. ការិយាល័យវិវាទ ..................... ២៦
៦. ការិយាល័យសហប្រតិបត្តិការ និងកិច្ចការច្បាប់ ..................... ២៧
៧. ការិយាល័យអប់រំ និងចំណេះដឹងសាធារណៈ ..................... ២៨
៨. ការិយាល័យរដ្ឋបាលទូទៅ ..................... ២៩
៩. ការិយាល័យស្វ័យប្រវត្តិកម្ម និងព័ត៌មានវិទ្យា ..................... ៣០
**ផ្នែកទី២៖ គុណសម្បត្តិ និងគុណវិបត្តិ** ..................... ៣២
**កថាភាគទី១៖ គុណសម្បត្តិ** ..................... ៣២
**កថាភាគទី២៖ គុណវិបត្តិ** ..................... ៣២

## ជំពូកទី៣

## ការរំលោភបំពានម៉ាក និងការដោះស្រាយវិវាទ

**ផ្នែកទី១៖ ការរំលោភលើម៉ាក** ..................... ៣៤
**កថាភាគទី១៖ ការប្រើប្រាស់ម៉ាកដោយគ្មានការយល់ព្រមពីម្ចាស់ម៉ាក** ..................... ៣៤
**កថាភាគទី២៖ ការក្លែងបន្លំម៉ាក** ..................... ៣៥
១. ការផលិតឡើងវិញនៃម៉ាក ..................... ៣៥
២. ការធ្វើត្រាប់តាមម៉ាក ..................... ៣៦

៣. ការច្រកផលិតផល ..... ៣៦
**ផ្នែកទី២៖ យន្តការដំណោះស្រាយ** ..... ៣៦
**កថាភាគទី១៖ វិធានការតាមមាត់ច្រកព្រំដែន** ..... ៣៦
**១. សមត្ថកិច្ចតាមច្រកព្រំដែន** ..... ៣៧
**២. ពាក្យបណ្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច** ..... ៣៧
**៣. ចំណាត់ការរបស់សមត្ថកិច្ចតាមច្រកព្រំដែន** ..... ៣៨
ក. ការជូនដំណឹងអំពីការព្យួរទុក ..... ៣៨
ខ. រយៈពេលនៃការព្យួរទុក ..... ៣៨
គ. សិទ្ធិត្រួតពិនិត្យ និងសិទ្ធិទទួលព័ត៌មាន ..... ៣៩
ឃ. សំណងចំពោះអ្នកនាំចូល និងចំពោះម្ចាស់ទំនិញ ..... ៤០
**៤.ការបំផ្លាញនូវទំនិញដែលពាក់ម៉ាកក្លែងក្លាយ** ..... ៤០
**កថាភាគទី២៖ ការដោះស្រាយវិវាទ** ..... ៤០
**១. ការដាក់ពាក្យបណ្តឹង** ..... ៤០
ក. ប្តឹងជំទាស់នឹងម៉ាកដែលបានដាក់ពាក្យសុំចុះបញ្ជី ..... ៤០
ខ. ប្តឹងជំទាស់នឹងម៉ាកដែលបានចុះបញ្ជីរួច ..... ៤០
គ. ប្តឹងមោឃភាពដល់ការចុះបញ្ជីម៉ាក ..... ៤១
ឃ. ប្តឹងពីបទរំលោភបំពានពាណិជ្ជ ឬសេវាសញ្ញា ..... ៤១
**២. ការពិនិត្យពាក្យបណ្តឹងជំទាស់ក្រោយចុះបញ្ជី** ..... ៤២
**៣. ការជូនដំណឹងអំពីពាក្យបណ្តឹង** ..... ៤២
**៤. ការស្នើសុំបើកសវនាការ** ..... ៤២
**៥. អានុភាពនៃសេចក្តីសម្រេច** ..... ៤៣
**សេចក្តីសន្និដ្ឋាន** ..... ៤៤
**អនុសាសន៍** ..... ៤៦
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជា បច្ចុប្បន្នជាប្រទេសមួយដែលមាន ឯករាជ្យ សន្តិភាព ហើយជាប្រទេសមួយកំពុងតែអភិវឌ្ឍន៍យ៉ាងខ្លាំងលើគ្រប់វិស័យទាំងអស់ ដូចជាបណ្តាប្រទេសដទៃទៀតនៅលើសកលលោកយើងនេះ ដែលកំពុងតែមានភាពជឿនលឿនលើគ្រប់វិស័យទាំងអស់ ជាពិសេសគឺវិស័យពាណិជ្ជកម្មនេះតែម្តង។ នាពេលបច្ចុប្បន្ននេះ យើងសង្កេតឃើញថា ប្រជាពលរដ្ឋខ្មែរមានការចាប់អារម្មណ៍យ៉ាងខ្លាំង ទៅលើកម្មសិទ្ធិបញ្ញា ពីព្រោះមិនថាប្រទេសណានោះទេ គឺមានការលួចចម្លងនៅស្នាដៃរបស់អ្នកដទៃ ហើយការលួចចម្លងនោះមានលក្ខណៈតិច ឬក៏ច្រើន ដូច្នេះហើយទើបប្រទេសនីមួយៗបង្កើតច្បាប់កម្មសិទ្ធិបញ្ញាឡើង ដើម្បីធ្វើការការពារស្នាដៃរបស់អ្នកដែលបានបង្កើត និងអ្នកដែលបានរកឃើញថ្មី។ ហេតុនេះ បានជាប្រព័ន្ធច្បាប់កម្មសិទ្ធិបញ្ញាបានដើរតួយ៉ាងសំខាន់ប្រៀបបានទៅនឹងចន្ទល់ ឬក៏អាវុធដ៏រឹងមាំ សម្រាប់ធ្វើការការពារនូវវិស័យពាណិជ្ជកម្មនៅកម្ពុជា។ ដើម្បីការពារកម្មសិទ្ធិបញ្ញាបានល្អ និងមានប្រសិទ្ធភាព គឺចាំបាច់បំផុត សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ក៏ដូចជាសម្រាប់ការជំរុញការវិនិយោគដោយផ្ទាល់ពីបរទេស ការផ្ទេរនិងការផ្សព្វផ្សាយបច្ចេកវិទ្យាក្នុងការបង្កើតការងារ និងប្រាក់ចំណូលក្នុងស្រុកព្រមទាំងសម្រួលដល់សមាហរណកម្មសេដ្ឋកិច្ចកម្ពុជា ទៅក្នុងសេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចពិភពលោក។ ដោយស្ថិតនៅក្នុងទិសដៅអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ កម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងកិច្ចប្រឹងប្រែងបញ្ជ្រាបវិស័យពាណិជ្ជកម្ម ទៅក្នុងគោលនយោបាយជាតិរបស់ខ្លួន ព្រមទាំងធ្វើការលើកកម្ពស់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចយ៉ាងទូលំទូលាយ ទាំងក្នុងតំបន់ និងសកលលោក រហូតមានការចូលជាសមាជិករបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកនៅក្នុងឆ្នាំ ១៩៩៥ ក៏ដូចជាការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកនៅឆ្នាំ២០០៤[១]។

ក្នុងឋានៈជាសមាជិកអង្គការកម្មសិទ្ធិបញ្ញាពិភពលោក កម្ពុជាក៏បានបង្កើតជាគណៈកម្មការគ្រប់គ្រងផ្នែកទាំងបីនៃកម្មសិទ្ធិបញ្ញានៅឆ្នាំ១៩៩៩[២]។ ម្យ៉ាងទៀត ដោយមើលឃើញពីគុណសម្បត្តិដ៏ធំធេងរបស់វិស័យកម្មសិទ្ធិបញ្ញា រាជរដ្ឋាភិបាលក៏បានធ្វើការបង្កើតជាគណៈកម្មាធិការជាតិថ្មីមួយ ជំនួសឱ្យគណៈកម្មការគ្រប់គ្រងផ្នែកទាំងបីនៃកម្មសិទ្ធិបញ្ញា[៣]។ ទន្ទឹមនឹងនោះ ក្រសួងពាណិជ្ជកម្មក៏បានបង្កើតជានាយកដ្ឋានជាច្រើន ដើម្បីធ្វើការសម្របសម្រួល គ្រប់គ្រង និងជួយរំលែកការងារទាំងឡាយរបស់ក្រសួង ជាពិសេសគឺជានាយកដ្ឋានកម្មសិទ្ធិ

[១] សន សោភ័ណ, "កម្មសិទ្ធិបញ្ញា និងសិទ្ធិនៃម្ចាស់កម្មសិទ្ធិបញ្ញា", (បទបង្ហាញនៅក្នុងសិក្ខាសាលាកម្មសិទ្ធិបញ្ញា, សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច, ២៦ មេសា ២០០៨)។

[២] សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងផ្នែកទាំងបីនៃកម្មសិទ្ធិបញ្ញា,លេខ១៦ សសរ, ២២ កុម្ភៈ ១៩៩៩។

[៣] អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា, លេខ១៩២ អ.ន.ក្រ.បក, ១៨ កញ្ញា ២០០៨។

បញ្ញានៅក្នុងឆ្នាំ២០១៤[៤]។ ចំពោះការបង្កើតនាយកដ្ឋានកម្មសិទ្ធិបញ្ញានេះឡើង ក្នុងបំណងធ្វើយ៉ាងណាឱ្យវិស័យកម្មសិទ្ធិបញ្ញានៅកម្ពុជាមានប្រសិទ្ធភាព និងមានការរីកចម្រើនជឿនលឿនដូចប្រទេសដទៃទៀត។

បើទោះបីជាមានការយកចិត្តទុកដាក់យ៉ាងខ្លាំង ទៅលើបញ្ហាកម្មសិទ្ធិបញ្ញាយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជា នៅតែមានការជួបប្រទះនូវឧសគ្គផ្នែកហិរញ្ញវត្ថុ និងសមត្ថភាពផ្នែកបច្ចេកទេសផងដែរ។ យ៉ាងណាមិញ រាជរដ្ឋាភិបាលបានធ្វើការខិតខំប្រឹងប្រែងយ៉ាងខ្លាំងទៅលើទំនើបកម្មច្បាប់កម្មសិទ្ធិបញ្ញា ដើម្បីដើរឱ្យទាន់ការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗអន្តរជាតិ។ ជាពិសេស រាជរដ្ឋាភិបាលបានទទួលស្គាល់នូវភាពចាំបាច់ផងដែរ ក្នុងការពង្រឹងយន្តការអនុវត្ត ដើម្បីប្រឆាំងនឹងការរំលោភបំពានវិស័យកម្មសិទ្ធិបញ្ញានេះ[៥]។ បញ្ហាទាំង ឡាយដែលបានកើតឡើងក្នុងវិស័យកម្មសិទ្ធិបញ្ញានេះ វាក៏អាចបណ្តាលមកពីនាយកដ្ឋានកម្មសិទ្ធិបញ្ញានៅកម្ពុជានាពេលបច្ចុប្បន្ននេះ នៅមិនទាន់មានភាពល្អប្រសើរនៅឡើយ ក្នុងការគ្រប់គ្រងលើផ្នែកកម្មសិទ្ធិបញ្ញារបស់ខ្លួនដែលទាមទារឱ្យមានការអភិវឌ្ឍន៍ខ្លួនបន្ថែមទៀតនៅក្នុងការគ្រប់គ្រងផ្នែកកម្មសិទ្ធិបញ្ញានេះ។

ដោយសារតែមានការមើលឃើញនៅរាល់ចំណុចខ្វះខាតមួយចំនួន ក៏ដូចជាចង់ដឹងអំពីតួនាទី និងភារកិច្ចរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានេះហើយ ទើបសារណាមួយនេះអាត្មាភាពខ្ញុំបាទនឹងធ្វើការសិក្សាទៅលើតួនាទី និងភារកិច្ចរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងវិភាគរិះរកនូវយន្តការគន្លឹះល្អៗផ្សេងទៀត ក្នុងការជួយបំពេញបន្ថែមឱ្យនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជាកាន់តែមានភាពរីកចម្រើន។

ពេលនេះអ្នកនឹងមានចម្ងល់ជាច្រើនទាក់ទងទៅនឹងប្រធាននេះថា៖

តើនាយកដ្ឋានកម្មសិទ្ធិបញ្ញាមានតួនាទី និងភារកិច្ចបែបណាខ្លះនៅក្នុងក្រសួងពាណិជ្ជកម្ម?

តើនាយកដ្ឋានកម្មសិទ្ធិបញ្ញាមានការរៀបចំនូវរចនាសម្ព័ន្ធរបៀបណាខ្លះ ដើម្បីឱ្យទទួលបាននូវដំណើរការល្អនិងប្រសិទ្ធភាពកាន់តែល្អប្រសើរឡើង?

តើមានការិយាល័យចំណុះចំនួនប៉ុន្មាន ដែលស្ថិតនៅក្រោមនាយកដ្ឋានកម្មសិទ្ធិបញ្ញា តួនាទី និងភារកិច្ចយ៉ាងណាខ្លះ?

ដូច្នេះ ដើម្បីធ្វើការសិក្សាឱ្យកាន់តែមានភាពលម្អិត និងកាន់មានភាពស៊ីជម្រៅឱ្យកាន់តែខ្លាំងថែមទៀតនោះ ចំពោះប្រធានបទក្នុងអត្ថបទសារណានេះ យើងនឹងធ្វើការសិក្សាស្រាវជ្រាវ នឹងធ្វើការបែងចែកចេញជាបីជំពូកគឺ៖

[៤] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម, លេខ១៣១. អនក្រ.បក, ១៩ មីនា ២០១៤។

[៥] ការពន្យល់ និងឧទាហរណ៍: កម្មសិទ្ធិបញ្ញា និងការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ទំព័រទី៣។

- ជំពូកទី១៖ សញ្ញាណទូទៅនៃកម្មសិទ្ធិបញ្ញា
- ជំពូកទី២៖ រចនាសម្ព័ន្ធ និងតួនាទីភារកិច្ច
- ជំពូកទី៣៖ ការរំលោភបំពានម៉ាក និងការដោះស្រាយវិវាទ។

# ជំពូកទី ១
# សញ្ញាណទូទៅនៃកម្មសិទ្ធិបញ្ញា

ទោះបីជាព្រះរាជាណាចក្រកម្ពុជា នៅមានភាពក្មេងខ្ចីក្នុងការប្រឡូកចូលទៅក្នុងឆាកអន្តរជាតិលើវិស័យពាណិជ្ជកម្មក៏ពិតមែនយ៉ាងណាក៏ដោយ ប៉ុន្តែកម្ពុជាបាននឹងកំពុងខិតខំប្រឹងប្រែងធ្វើកិច្ចសហប្រតិបត្តិការយ៉ាងសកម្ម ជាមួយនឹងប្រទេសដែលជាដៃគូនានា ដើម្បីសកលភាវូបនីយកម្មវិស័យពាណិជ្ជកម្មរបស់ខ្លួនឱ្យមានលក្ខណៈជាអន្តរជាតិ និងស្របទៅតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនឹងការពង្រឹងផ្នែកពាណិជ្ជកម្មឱ្យមានភាពរីកចម្រើនទៅបាននោះ ចាំបាច់ណាស់ត្រូវពង្រឹងវិស័យកម្មសិទ្ធិបញ្ញាផងដែរ ព្រោះថាវិស័យនេះមានទិសដៅសំខាន់ក្នុងការជំរុញនិងការពារជាចន្ទល់នៃពាណិជ្ជកម្មឱ្យមានភាពរឹងមាំ និងមានការរីកចម្រើនដូចទៅនឹងប្រទេសដទៃទៀត។

## ផ្នែកទី ១
## ប្រវត្តិនៃកម្មសិទ្ធិបញ្ញានៅព្រះរាជាណាចក្រកម្ពុជា

### កថាភាគទី១៖ សាវតា

នៅក្នុងព្រះរាជាណាចក្រកម្ពុជា កម្មសិទ្ធិបញ្ញាបានចាប់កំណើតមានតាំងពីក្នុងទសវត្សទី៦០ និង ៧០ មកម្ល៉េះ ហើយម៉ាកមួយចំនួនក៏បានទទួលកិច្ចការពារនៅក្នុងកំឡុងពេលនោះដែរ ដូចជា ម៉ាក PERTUSSIN ស្ថិតនៅក្នុងជំពូកទី៥ ដែលមានលេខដាក់ពាក្យ ១៩៧៣ នៅក្នុងឆ្នាំ១៩៦៦ ហើយ ម៉ាក RIBENA ស្ថិតក្នុងជំពូកទី៥ និង៣២ ដែលមានលេខដាក់ពាក្យ ១០៣១៨ នៅក្នុងឆ្នាំ១៩៧៣។ ជាអកុសល ក្រោយមក ប្រទេសកម្ពុជាបានជួបនូវវិបត្តិសង្គ្រាមក្នុងស្រុកដ៏ធ្ងន់ធ្ងរ ដែលធ្វើអោយវិស័យកម្មសិទ្ធិបញ្ញា ត្រូវបានបោះបង់ចោលអស់រយៈពេលជិត ២ ទសវត្ស។ ដោយមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស នៅថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៩៩១ ប្រទេសកម្ពុជាបានចាប់ផ្ដើមស្តារហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិឡើងវិញ ដែលនាំអោយវិស័យកម្មសិទ្ធិបញ្ញាត្រូវបានដំណើរការឡើងវិញ។ ជាលទ្ធផល នៅឆ្នាំ ១៩៩១ ការិយាល័យពាណិជ្ជសញ្ញា ត្រូវបានបង្កើតឡើងនៅក្រោមការគ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្ម ដែលមានភារកិច្ចទទួលចុះបញ្ជី និងការពារពាណិជ្ជសញ្ញា និងទទួលបានការគាំទ្រ និងជួយឧបត្ថម្ភជ្រោមជ្រែងបណ្តុះបណ្តាល ផ្នែកបច្ចេកទេសពីប្រទេសនានាជាពិសេស អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដែលមានមូលដ្ឋាននៅក្នុងទីក្រុងហ្សឺណែវនៃប្រទេសស្វីស។

### កថាភាគទី២៖ ស្ថាបនិក

យោងទៅតាមអនុក្រឹត្យនៃរាជរដ្ឋាភិបាលកម្ពុជាលេខ ៥៤ ចុះនៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវបានបង្កើតឡើង។ នៅមុនការបង្កើតនាយកដ្ឋាននេះ នាយកដ្ឋាន

ពាណិជ្ជកម្មក្រៅប្រទេស ទទួលតួនាទីចុះបញ្ជី និងការពារម៉ាក។ នាយកដ្ឋានកម្មសិទ្ធិបញ្ញា មានភារកិច្ច និងទទួលខុសត្រូវលើ ៖ ការសិក្សា វិភាគ និងផ្តល់អនុសាសន៍អំពីគោលនយោបាយកម្មសិទ្ធិបញ្ញា ជូនដល់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងរដ្ឋាភិបាលកម្ពុជា សម្របសម្រួល និងរៀបចំច្បាប់ ព្រមទាំងបទបញ្ញត្តិកម្មសិទ្ធិបញ្ញា សម្របសម្រួលកិច្ចសហប្រតិបត្តិការ និងជំនួយក្នុងវិស័យកម្មសិទ្ធិបញ្ញាជាមួយសហគមន៍អន្តរជាតិ ត្រួតពិនិត្យមើលវិស័យទាំងបីនៃកម្មសិទ្ធិបញ្ញាក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើជាចំណុចប្រសព្វនៃកម្មសិទ្ធិបញ្ញា និងសម្របសម្រួលបញ្ហាកម្មសិទ្ធិបញ្ញាទាំងអស់ ជាមួយក្រសួងពាក់ព័ន្ធ ជំរុញផ្សព្វផ្សាយតាមគ្រប់មធ្យោបាយនានា ដើម្បីការពារកម្មសិទ្ធិបញ្ញាអោយបានត្រឹមត្រូវ និងមានប្រសិទ្ធិភាព អនុវត្តរាល់កាតព្វកិច្ចទាំងអស់ ដែលមានចែងក្នុងកិច្ចព្រមព្រៀង និងអនុសញ្ញាផ្សេងៗ។

ចាប់តាំងពីឆ្នាំ១៩៩៤ ដល់ ឆ្នាំ១៩៩៨ នាយកដ្ឋានកម្មសិទ្ធិបញ្ញាបានទទួលចុះបញ្ជីម៉ាកចំនួន ៧០៥៥ ដែលនៅក្នុងនោះម៉ាក ក្នុងស្រុកមានចំនួន ១៩៨ និង ម៉ាកបរទេសមានចំនួន ៦៨៥៥ ។ ទោះបីវិស័យកម្មសិទ្ធិបញ្ញាជាបញ្ហាថ្មីស្រឡាង ចំពោះព្រះរាជាណាចក្រកម្ពុជាយើងក៏ដោយ ប៉ុន្តែដោយបានទទួលការជួយឧបត្ថម្ភផ្នែកបច្ចេកទេសពីអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ក្នុងការបណ្តុះបណ្តាលធនធានមនុស្សទាំងនៅក្រៅប្រទេស និងក្នុងប្រទេស តាមរូបភាពហ្វឹកហ្វឺនរយៈពេលខ្លី និងសិក្ខាសាលាជាតិ ឬវេទិការអន្តរជាតិស្តីអំពីកម្មសិទ្ធិបញ្ញា និងការផ្តល់ជាសម្ភារៈបរិក្ខារបច្ចេកទេស នាយកដ្ឋានកម្មសិទ្ធិបញ្ញាអនុវត្តបាននូវតួនាទីរបស់ខ្លួន ក្នុងការទទួលចុះបញ្ជី និង កិច្ចការពារពាណិជ្ជសញ្ញា-សេវាសញ្ញាក្នុងស្រុក និងបរទេស។ ក្រោមការគ្រប់គ្រង និងដឹកនាំដោយលោក លី ផាណ្ណា ចាប់ពីឆ្នាំ១៩៩៧ ដល់ ២០០៤ ដែលក្រោយមក លោកកាន់តំណែងជាអគ្គនាយកនៃក្រសួងពាណិជ្ជកម្ម និងជាតំណាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មប្រចាំតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ នាយកដ្ឋានបានទទួលសមិទ្ធិផលល្អ គួរអោយកត់សម្គាល់ ដោយបានធ្វើអោយសាធារណៈជនស្គាល់ទាំងក្នុងស្រុក និងក្រៅស្រុក តាមរយៈការចុះបញ្ជី និងការការពារកម្មសិទ្ធិបញ្ញា និងតាមរយៈការយល់ដឹងជាសាធារណៈ សកម្មភាពចុះអនុវត្តច្បាប់ ព្រមទាំងសហការជាមួយស្ថាប័នជាតិ និងអន្តរជាតិ។ នាពេលនោះ នាយកដ្ឋានមានបុគ្គលិកសរុបប្រមាណ ៤០ រូប និងមានការិយាល័យចំណុះចំនួន ២ គឺការិយាល័យចុះបញ្ជីម៉ាក និងការិយាល័យផ្សព្វផ្សាយ និងពត៌មាន ។ ទោះបីជាយ៉ាងណាក៏ដោយ បើប្រៀបធៀបនឹងសម័យបច្ចុប្បន្ន នៅក្នុងកំឡុងពេលនោះ ការងារកម្មសិទ្ធិបញ្ញានៅមានទំហំតូច ដែលបានទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកចំនួនពី ១៥០០ ២០០០ ម៉ាក (ភាគច្រើន លើសលុប គឺជាម៉ាករបស់បរទេស) និងម៉ាកអាចចុះបញ្ជីបានចំនួនប្រហែល ១៥០០ ម៉ាកក្នុង ១ ឆ្នាំៗ។ ជាងនេះទៅទៀត ទាំងឧបករណ៍ ប្រើប្រាស់នៅក្នុងការិយាល័យ និងចំណេះដឹងរបស់បុគ្គលនៅមានកំរិតនៅឡើយ ដោយប្រើម៉ាស៊ីនអង្គុលីលេខដើម្បីវាយអត្ថបទ ឬឯកសារផ្សេងៗ។ល។

## កថាភាគទី៣៖ គណៈកម្មាធិការគ្រប់គ្រងផ្នែកទាំងបីនៃកម្មសិទ្ធិបញ្ញា

ទោះបីវិស័យកម្មសិទ្ធិបញ្ញាជាបញ្ហាថ្មីស្រឡាង ចំពោះព្រះរាជាណាចក្រកម្ពុជាយើងក៏ដោយ ប៉ុន្តែដោយបានទទួលការជួយឧបត្ថម្ភផ្នែកបច្ចេកទេសពីអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ក្នុងការបណ្តុះបណ្តាលធនធានមនុស្សទាំងនៅក្រៅប្រទេស និងក្នុងប្រទេស តាមរូបភាពហ្វឹកហ្វឺនរយៈពេលខ្លី និងសិក្ខាសាលាជាតិ ឬវេទិការអន្តរជាតិស្តីអំពីកម្មសិទ្ធិបញ្ញា និងការផ្តល់ជាសម្ភារៈបរិក្ខារបច្ចេកទេស នាយកដ្ឋានកម្មសិទ្ធិបញ្ញាអនុវត្តន៍នូវតួនាទីរបស់ខ្លួន ក្នុងការទទួលចុះបញ្ជី និងកិច្ចការពារពាណិជ្ជសញ្ញា-សេវាសញ្ញាក្នុងស្រុក និងបរទេស។ អស់រយៈពេលជិត ២ ឆ្នាំក្រោយមក ដោយយោងតាមសំណើរបស់ក្រសួងពាណិជ្ជកម្ម និង ក្នុងគោលបំណងអោយមាននយោបាយកម្មសិទ្ធិបញ្ញារបស់ជាតិតែមួយ រាជរដ្ឋាភិបាលកម្ពុជាបានចេញសេចក្តីសម្រេចលេខ១៦ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ១៩៩៩ បង្កើត "គណៈកម្មាធិការគ្រប់គ្រងផ្នែកទាំងបីនៃកម្មសិទ្ធិបញ្ញា"[៦] ដោយមានរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មជាប្រធាន និងនាយកដ្ឋានកម្មសិទ្ធិបញ្ញាត្រូវបានជ្រើសតាំងជាលេខាធិការដ្ឋាននៃគណៈកម្មាធិការ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាអនុប្រធាន ចំណែករដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ព្រមទាំងក្រសួងព័ត៌មានជាសមាជិក។ ភារកិច្ចរបស់គណៈកម្មាធិការនេះគឺ៖ ពន្លឿន សេចក្តីព្រៀងច្បាប់ និងបទបញ្ញត្តិទាំងអស់ ដែលពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញា ដើម្បីបំពេញកាតួកិច្ចរបស់ប្រទេសកម្ពុជា ក្នុងការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក សម្របសម្រួលបញ្ហាកម្មសិទ្ធិបញ្ញាទាំងអស់ រវាងក្រសួងពាក់ព័ន្ធខាងលើ។

ដោយផ្អែកលើភារកិច្ចខាងលើ គណៈកម្មាធិការ និងលេខាធិការដ្ឋានបានកោះប្រជុំជាច្រើនលើក ដើម្បីរកវិធីពន្លឿនសេចក្តីព្រាងច្បាប់កម្មសិទ្ធិបញ្ញា និងបែងចែកការទទួលខុសត្រូវរវាងក្រសួងពាក់ព័ន្ធផ្សេងៗ។

ទន្ទឹមនឹងកំណើននេះ កិច្ចសហប្រតិបត្តិការរវាងនាយកដ្ឋានកម្មសិទ្ធិបញ្ញា និងដៃគូអភិវឌ្ឍន៍នៅក្រៅប្រទេសជាច្រើន ត្រូវបានពង្រឹងកាន់តែខ្លាំង ដោយទទួលបានជំនួយបច្ចេកទេសទាំងផ្នែកច្បាប់ និងសម្ភារៈ ជាបន្តបន្ទាប់ ដែលនាំអោយកេរ្តិ៍ឈ្មោះរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវបានទទួលស្គាល់នៅលើឆាកអន្តរជាតិ ដូចជា អង្គការកម្មសិទ្ធិបញ្ញាពិភពលោក គម្រោងសហប្រតិបត្តិការសហគមន៍អឺរ៉ុប-អាស៊ានលើការការពារកម្មសិទ្ធិបញ្ញា ការិយាល័យប្រកាសនីយបត្រតក្កកម្មរបស់ជប៉ុន ការិយាល័យម៉ាក និងប្រកាសនីយបត្រតក្កកម្មរបស់សហរដ្ឋអាមេរិកជាដើម។

ជាងនេះទៅទៀត កម្លាំងធនធានមនុស្ស និងទំហំនាយកដ្ឋាន ចាំបាច់ត្រូវតែពង្រីក។ នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៧ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបានចេញប្រកាស ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃនាយកដ្ឋាន

[៦] សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងផ្នែកទាំងបីនៃកម្មសិទ្ធិបញ្ញា,លេខ១៦ សសរ, ២២ កុម្ភៈ ១៩៩៩។

កម្មសិទ្ធិបញ្ញា ដោយសម្រេចបង្កើតការិយាល័យចំនួន៤ ទៀត គឺ ៖ការិយាល័យក្រោយចុះបញ្ជីម៉ាក ការិយាល័យម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនិងពត៌មានសម្ងាត់ការិយាល័យវិវាទ ការិយាល័យសហប្រតិបត្តិការ និងកិច្ចការច្បាប់។

## កថាភាគទី៤ ៖ គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា

រយៈពេល ៨ ឆ្នាំក្រោយពេលកម្ពុជាយើងបានចូលជាសមាជិក នៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ការត្រៀមខ្លួនអនុវត្តន៍កិច្ចព្រមព្រៀងកម្មសិទ្ធិបញ្ញាពាក់ព័ន្ធនឹងពាណិជ្ជកម្ម ត្រូវបានពង្រឹង ដែលស្របទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់ទី២របស់រាជរដ្ឋាភិបាលគឺ "ការពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា"។ ដើម្បីបង្រួមការធ្វើគោលនយោបាយ ការពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា និងជំនួយបច្ចេកទេស រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យស្តីពី "ការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា" លេខ ១៤២ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០០៨ ជំនួសសេចក្តីសម្រេចចាស់តាំងពីឆ្នាំ១៩៩៩ ដោយមាននាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ជាលេខាធិការដ្ឋាន។ គណៈកម្មាធិការនេះ ទទួលខុសត្រូវបង្កើតគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា ពង្រឹងកិច្ចសហប្រតិបត្តិការរវាងភ្នាក់ងារឬស្ថាប័នផ្សេងៗ រៀបចំផ្សព្វផ្សាយច្បាប់ និងបទបញ្ញត្តិថ្មីៗ និងធ្វើជាចំណុចរួមមួយក្នុងការទទួលជំនួយបច្ចេកទេស។ គណៈកម្មាធិការជាតិនេះ មានភារកិច្ចបន្ថែមលើសពីគណៈកម្មាធិការគ្រប់គ្រងផ្នែកទាំងបីនៃកម្មសិទ្ធិបញ្ញា គ្រង់សហការផ្សព្វផ្សាយច្បាប់កម្មសិទ្ធិបញ្ញាជូន ដល់មន្ត្រីរាជការ និស្សិត ស្ថាប័នអប់រំ សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងតុលាការ ដើម្បីទប់ស្កាត់ការរំលោភបំពានកម្មសិទ្ធិបញ្ញា ព្រមទាំងសិក្សាអំពីកិច្ចព្រមព្រៀង និងសន្ធិសញ្ញាអន្តរជាតិនានា ដើម្បីរកចំណុចខ្លាំង និងចំណុចខ្សោយ។

ដោយផ្អែកលើភារកិច្ច ដែលមានចែងនៅក្នុងអនុក្រឹត្យ នាយកដ្ឋានកម្មសិទ្ធិបញ្ញាដែលជាលេខាធិ-ការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា បានសហការជាមួយអង្គការ រៀបចំផែនការសកម្មភាពមួយចំនួន ក្នុងគោលដៅជាក់លាក់មួយ ដើម្បីបង្កើតប្រព័ន្ធកម្មសិទ្ធិបញ្ញាជាតិដ៏ខ្លាំងមួយ សម្រាប់ការពារកម្មសិទ្ធិបញ្ញា ការគ្រប់គ្រង និងការអនុវត្តច្បាប់អោយស្របទៅនឹងស្តង់ដារកម្មសិទ្ធិបញ្ញាអន្តរជាតិ និងគាំទ្រគោលដៅអភិវឌ្ឍន៍ពាណិជ្ជកម្មរបស់រាជរដ្ឋាភិបាល ។ នាពេលបច្ចុប្បន្ន នាយកដ្ឋានកម្មសិទ្ធិបញ្ញាកំពុងមានទិសដៅទៅមុខបន្ថែមទៀត ដោយធ្វើសេចក្តីព្រាងអនុក្រឹត្យមួយស្តីពីការពង្រឹងការអនុវត្តន៍ច្បាប់កម្មសិទ្ធិបញ្ញា ការអប់រំ និងផ្សព្វផ្សាយ។

## កថាភាគទី៥ ៖ ក្របខណ្ឌច្បាប់

ចាប់តាំងពីមានការឯកភាពជាតិនាឆ្នាំ១៩៩១មក ប្រទេសកម្ពុជាមានគោលនយោបាយកម្មសិទ្ធិបញ្ញាឡើងវិញ នៅពេលដែលពាណិជ្ជករ និងវិនិយោគិនបរទេសជាច្រើន បានស្នើសុំមកក្រសួងពាណិជ្ជកម្ម និងក្រុម

ប្រឹក្សារដ្ឋមន្ត្រី អោយតម្កល់ទុកជាផ្លូវការ នូវស្លាកសញ្ញាទំនិញរបស់ពួកគេ។ គោលគំនិតសំខាន់នៃគោលនយោបាយកម្មសិទ្ធិបញ្ញាកម្ពុជាចាប់ពីឆ្នាំ ១៩៩១ ដល់ ឆ្នាំ ២០០៣ គឺរៀបចំច្បាប់និងបទប្បញ្ញត្តិស្តីពីម៉ាក ប្រកាសនីយបត្រតក្កកម្ម និងសិទ្ធិអ្នកនិពន្ធ ដើម្បីអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួននៅក្រោមកិច្ចព្រមព្រៀង TRIPS នៃអង្គការពាណិជ្ជកម្មពិភពលោក ។ គោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីពីររបស់រាជរដ្ឋាភិបាលកម្ពុជាគឺ ធ្វើឱ្យច្បាប់កម្មសិទ្ធិបញ្ញាស្របទៅនឹងសេចក្តីត្រូវការនៃការអភិវឌ្ឍន៍របស់ប្រទេស ជាពិសេស ក្នុងវិស័យអប់រំកសិកម្ម និងសុខភាព។ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកការការពារកម្មសិទ្ធិបញ្ញាថា មានសារៈសំខាន់ ដល់ការលើកស្ទួយការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ជម្រុញការវិនិយោគទុនបរទេស និងការផ្ទេរបច្ចេកវិទ្យា ព្រមទាំងសម្រួលដល់សមាហរណកម្មរបស់ប្រទេសកម្ពុជា ចូលទៅក្នុងសេដ្ឋកិច្ចពិភពលោក ។

ដំបូងឡើយ កិច្ចការពារកម្មសិទ្ធិបញ្ញារបស់ប្រទេសកម្ពុជា ផ្អែកលើមាត្រា ៤៧ និង៤៨ នៃបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងច្បាប់ និងនីតិវិធីព្រហ្មទណ្ឌ តុលាការដែលអាចអនុវត្តបានក្នុងប្រទេស កម្ពុជានៅក្នុងសម័យអន្តរកាលរបស់អាជ្ញាធរបណ្តោះអាសន្ន នៃអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ១៩៩២ និង ប្រកាសលេខ ៣៦៨ របស់ក្រសួងពាណិជ្ជកម្ម នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីនីតិវិធីរបស់នាយក-ដ្ឋានកម្មសិទ្ធិបញ្ញា ដែលមានបំណងធានាដល់កិច្ចការពារកម្មសិទ្ធិបញ្ញា ដែលបានត្រួសត្រាយផ្លូវដល់ការចូលជាសមាជិករបស់អង្គការ WTO ក្នុងឆ្នាំ ២០០៤។ នៅក្នុងសេចក្តីប្រកាសនេះ នាយកដ្ឋានមានសិទ្ធិធ្វើការចុះបញ្ជី និងផ្តល់វិញ្ញាបនបត្រពាណិជ្ជសញ្ញា និងសេវាសញ្ញា ជូនដល់ពាណិជ្ជករនិងអ្នកវិនិយោគ ទាំងក្នុងស្រុក និងក្រៅប្រទេស ព្រមទាំងដោះស្រាយរាល់បញ្ហាទាំងអស់ ដែលកើតឡើងពីការចុះបញ្ជីនេះ។ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ ២០០០ ក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានចេញកំណត់ហេតុនៃ ការព្រមព្រៀងផ្ទេរភារកិច្ចនៃការគ្រប់គ្រង និងចុះបញ្ជីការពារម៉ាកនៃផលិតផលក្នុងស្រុក ដោយផ្ទេរភារកិច្ចគ្រប់គ្រង ចុះបញ្ជី ការពារម៉ាកក្នុងស្រុក ដែលពីមុនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អោយស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ក្រសួងពាណិជ្ជកម្មវិញ ។ ដូច្នេះរាល់បញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងម៉ាក គឺជាការទទួលខុសត្រូវតែមួយគត់របស់ក្រសួងពាណិជ្ជកម្ម។ បច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជាមានច្បាប់ទាក់ទងនឹងកម្មសិទ្ធិបញ្ញាចំនួន ៤ គឺ៖

- ទី១. ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រគួតប្រជែងមិនស្មោះត្រង់ ដែលត្រូវបានប្រកាសឱ្យប្រើប្រាស់ នៅថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០០២ បានបញ្ជាក់ពីភារកិច្ចរបស់ក្រសួងពាណិជ្ជកម្មចំពោះម៉ាក។ ក្រសូងពាណិជ្ជកម្មមិនមែនគ្រប់គ្រងផ្តាច់មុខនូវរាល់បញ្ហាទាំងអស់ ដែលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាទេ។
- ទី២. ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ត្រូវបាន

គ្រប់គ្រងដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ ច្បាប់នេះត្រូវបានប្រកាសឱ្យប្រើប្រាស់ នៅថ្ងៃទី ២២ ខែមករា ឆ្នាំ២០០៣ នៅពេលដែលក្រសួងនេះកំពុងរៀបចំបទបញ្ញត្តិ ដូចជា អនុក្រឹត្យ ឬប្រកាសសម្រាប់អនុវត្តច្បាប់នេះ

- ទី៣. ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដែលបានប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០០៣ ត្រូវបានគ្រប់គ្រងដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈសម្រាប់ការពារសិទ្ធិនេះ។
- ទី៤. ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានអនុម័ត នៅថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០០៨ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ។

# ផ្នែកទី ២

# ក្រសួងជំនាញកម្មសិទ្ធិបញ្ញា

វិស័យកម្មសិទ្ធិបញ្ញា ជាសញ្ញាណថ្មីមួយសម្រាប់ព្រះរាជាណាចក្រកម្ពុជា ហេតុដូច្នេះហើយ ក្នុងការដំណើរការ និងការប្រព្រឹត្តទៅចាំបាច់ត្រូវមានការចូលរួមសហការជាមួយ បណ្តាក្រសួងពាក់ព័ន្ធមួយចំនួន។ ដោយសារតែកម្មសិទ្ធិបញ្ញាមានមែកធាងច្រើន ដែលចាំបាច់បំផុតត្រូវតែមានការចូលរួមពីក្រសួងជំនាញណាមួយមកគ្រប់គ្រងផ្នែកនេះ ហេតុនេះហើយ បានជារាជរដ្ឋាភិបាលផ្តល់អំណាចទៅឱ្យក្រសួងសំខាន់ៗចំនួនបីគឺ ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងវិប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីក្នុងការចូលរួមពង្រឹងផ្នែកកម្មសិទ្ធិឱ្យមានភាពច្បាស់លាស់ និងជួយជំរុញផ្នែកសេដ្ឋកិច្ចជាតិឱ្យមានភាពជឿនលឿន។

## កថាភាគទី១៖ ក្រសួងពាណិជ្ជកម្ម

ក្រសួងពាណិជ្ជកម្ម បំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើបេសកកម្មដឹកនាំនិងរៀបចំគ្រប់គ្រងវិស័យពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា។ បេសកកម្មនេះ ត្រូវបានធ្វើឡើងតាមរយៈការរៀបចំ និងការអនុវត្តឱ្យបានត្រឹមត្រូវ នូវគោលនយោបាយក្របខណ្ឌច្បាប់ និងបទបញ្ញាទាំងឡាយដែលទាក់ទង នឹងវិស័យពាណិជ្ជកម្ម[៧]។

ក្រសួងពាណិជ្ជកម្ម គឺជាស្ថាប័នមួយដែលទទួលខុសត្រូវ ក្នុងការសម្របសម្រួលការងារកម្មសិទ្ធិបញ្ញា និងជាលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ដោយក្រសួងធ្វើការគ្រប់គ្រងលើម៉ាកពាណិជ្ជនាម និងការប្រកួតប្រជែងមិនស្មោះត្រង់ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកបញ្ជាក់

[៧] អនុក្រឹតស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម, លេខ១៣១ អបក.ក្រ.ន., មាត្រា៥។

អំពីចរិកលក្ខណៈនៃទំនិញ និងសេវាកម្ម និងការការពារព័ត៌មានសម្ងាត់ពាណិជ្ជកម្ម[៨]។ នៅក្នុងការគ្រប់គ្រងកម្មសិទ្ធិបញ្ញា ក្រសួងបានប្រគល់ភារកិច្ចទៅឱ្យនាយកដ្ឋានកម្មសិទ្ធិបញ្ញាដែលស្ថិតនៅក្រោមអគ្គនាយកដ្ឋានសេវាពាណិជ្ជនៃក្រសួងពាណិជ្ជកម្ម[៩]។

## ១. នាយកដ្ឋានកម្មសិទ្ធិបញ្ញា

នាយកដ្ឋានកម្មសិទ្ធិបញ្ញា ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ដោយមានការិយាល័យចំណុះចំនួន ៩ ការិយាល័យរួមមាន ការិយាល័យចុះបញ្ជីម៉ាកពាណិជ្ជកម្ម ការិយាល័យចុះម៉ាកបញ្ជីម៉ាកអន្តរជាតិ ការិយាល័យក្រោយចុះបញ្ជីម៉ាកពាណិជ្ជកម្ម ការិយាល័យម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងព័ត៌មានសម្ងាត់ពាណិជ្ជកម្ម ការិយាល័យវិវាទ ការិយាល័យសហប្រតិបត្តិការ និងកិច្ចការច្បាប់ ការិយាល័យអប់រំ និងចំណេះដឹងសាធារណៈ ការិយាល័យរដ្ឋបាលទូទៅ ការិយាល័យស្វ័យប្រវត្តិកម្ម និងព័ត៌មានវិទ្យា[១០]។ នាយកដ្ឋានកម្មសិទ្ធិបញ្ញាមានតួនាទី និងភារកិច្ចមួយចំនួនដូចជា៖

- ជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញាកម្ពុជា
- សហការ និងជំរុញក្រសួងពាក់ព័ន្ធចងក្រង និងអនុវត្តច្បាប់កម្មសិទ្ធិបញ្ញាស្របតាមការសន្យាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជា
- សហការជាមួយក្រសួងពាក់ព័ន្ធទទួល និងប្រើប្រាស់ជំនួយបច្ចេកទេស ពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញា ពីអង្គការអន្តរជាតិ និងប្រទេសនានា
- ទទួលបន្ទុកជាចំណុចកណ្តាល ក្នុងការសម្របសម្រួលកិច្ចសហប្រតិបត្តិការទ្វេភាគី ឬពហុភាគីលើវិស័យកម្មសិទ្ធិបញ្ញា ជាមួយបណ្តាប្រទេស និងអង្គការអន្តរជាតិផ្សេងៗ
- សហការជាមួយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវនៃក្រសួងពាណិជ្ជកម្ម ក្រសួងស្ថាប័ននានាផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិនានា និងចំណេះដឹងកម្មសិទ្ធិបញ្ញាដល់មហាជន ស្ថាប័នអប់រំ និងមន្ត្រីអនុវត្តច្បាប់
- ទទួលអនុវត្ត និងសហការរៀបចំច្បាប់ និងបទប្បញ្ញត្តិទាក់ទាក់ទងនឹងកម្មសិទ្ធិបញ្ញាដូចខាងក្រោម៖
  - ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រគួតប្រជែងមិនស្មោះត្រង់
  - ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
  - កិច្ចការពារព័ត៌មានសម្ងាត់ និងសម្ងាត់ពាណិជ្ជកម្ម

[៨] អនុក្រឹតស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម, លេខ១៣១ អបក.ក្រ.ន., មាត្រា៥។

[៩] អនុក្រឹតស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម, លេខ១៣១ អបក.ក្រ.ន., មាត្រា៧។

[១០] អង្គការលេខរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១។

- ការផ្ទេរអាជ្ញាប័ណ្ណ និងសិទ្ធិធ្វើអាជីវកម្ម
- កម្មសិទ្ធិបញ្ញាផ្សេងៗទៀតដែលជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម

- ចុះបញ្ជីម៉ាក ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកបញ្ជាក់អំពីចរិកលក្ខណៈទំនិញ និងសេវា (Certification Mark) ព្រមទាំងកត់ត្រាការផ្តល់អាជ្ញាប័ណ្ណ និងការផ្តល់សិទ្ធិអាជីវកម្មម៉ាក
- ចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិ
- ចេញលិខិតទទួលស្គាល់សិទ្ធិនាំចូលទំនិញផ្ទាល់មុខលើម៉ាក តាមសំណូមពររបស់ម្ចាស់ម៉ាកស្រប ច្បាប់
- សហការជាមួយអង្គភាព មន្ទីរពាក់ព័ន្ធ ក្នុងការទទួលពាក្យចុះបញ្ជី និងដោះស្រាយវិវាទអំពីម៉ាក ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកបញ្ជាក់អំពីចរិកលក្ខណៈទំនិញ និងសេវា (Certification Mark)
- ដោះស្រាយវិវាទនានា ទាក់ទងនឹងកម្មសិទ្ធិបញ្ញា ដែលជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងស្ថាប័នតុលាការ ដើម្បីបញ្ឈប់ការរំលោភកម្មសិទ្ធិបញ្ញា
- បង្កើត និងគ្រប់គ្រងគេហទំព័រកម្មសិទ្ធិបញ្ញា ក្នុងគោលបំណងផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិនានា ព្រមទាំងទិន្នន័យកម្មសិទ្ធិបញ្ញាដែលបានចុះបញ្ជីរួច
- ចូលរួមសិក្សាស្រាវជ្រាវកិច្ចព្រមព្រៀង និងអនុសញ្ញាអន្តរជាតិនានា ដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា និងធ្វើការពិចារណាលើប្រយោជន៍ជាតិ ក្នុងការចូលជាសមាជិកព្រមព្រៀង ឬអនុសញ្ញាទាំងនោះ
- ជំរុញការធ្វើពាណិជ្ជកម្មកម្មសិទ្ធិបញ្ញា និងការវាយតម្លៃទ្រព្យសម្បត្តិកម្មសិទ្ធិបញ្ញា ដែលជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម

ជាពិសេស នាយកដ្ឋានកម្មសិទ្ធិបញ្ញាអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន[១១]។ សមិទ្ធផលចម្បងៗ របស់នាយកដ្ឋានកម្មសិទ្ធិបញ្ញាមានដូចជា ការរៀបចំច្បាប់ និងបទប្បញ្ញត្តិនានា ការងារបណ្តុះបណ្តាល និងការងារចុះបញ្ជី។

## ២. ការរៀបចំច្បាប់ និងបទប្បញ្ញត្តិ

នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម បានរៀបចំច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ២០០២។ នាយកដ្ឋាន ក៏បានរៀបចំអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ម៉ាក ដែលត្រូវបានអនុម័តនៅឆ្នាំ២០០៦[១២]។ រៀបចំសេចក្តីព្រាងច្បាប់អនុក្រឹត្យ ស្តីពីការបង្កើតអនុគណៈ

[១១] ប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា, លេខ២០៦ ពប្រក.បល.ណ., ២៤ កក្កដា ២០១៤, ប្រការ១។

[១២] ពិន សុវិចិត្រ, វគ្គបណ្តុះបណ្តាលសម្រាប់ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក។

កម្មាធិការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា និងអនុគណៈកម្មាធិការអប់រំនិងផ្សព្វផ្សាយ ដែលបានដាក់ស្នើទៅទីស្តីការគណៈរដ្ឋមន្ត្រី តាំងពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២។ ដោយលើសពីនេះទៅទៀត នាយកដ្ឋានកម្មសិទ្ធិបានសហការជាមួយ នាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល ក្នុងការរៀបចំព្រាងច្បាប់អនុក្រឹត្យស្តីពី ការបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួម[១៣] ដែលបានស្នើទៅទីស្តីការគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១២ ក្នុងគោលបំណងប្រមូលនូវផលចំណេញដល់អ្នកសម្តែង និងអ្នកផលិតហ្វូណូក្រាម។

នាយកដ្ឋានកម្មសិទ្ធិបញ្ញា បានរៀចបំសេចក្តីព្រាងច្បាប់ស្តីពី ការផ្តល់អាជ្ញាប័ណ្ណបញ្ជាសម្រាប់សុខភាពសាធារណៈ ដែលបានពិនិត្យចប់សព្វគ្រប់នៅឆ្នាំ ២០១៣ ដោយក្រសួងសុខាភិបាល[១៤] ហើយសេចក្តីព្រាងច្បាប់នេះបានដាក់ស្នើទៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុញ្ញាត។ ច្បាប់នេះធ្វើឡើងក្នុងគោលបំណងជាសារៈប្រយោជន៍ដល់សុខមាលភាពប្រជាជន ដោយផ្តល់សិទ្ធិក្នុងការផលិតឱសថទូទៅនៅកម្ពុជា ក៏ដូចជាការនាំចេញ ការនាំចូលនូវប្រភេទឱសថចាំបាច់ ក្នុងការបម្រើឱ្យវិស័យសុខាភិបាល។ ជាពិសេស ក្រសួងបានរៀបចំសេចក្តីព្រាងយុត្តិសាស្ត្រជាតិកម្មសិទ្ធិបញ្ញា ដែលត្រូវបានកែតម្រូវ ដោយលេខាដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ហើយបានផ្ញើទៅឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងក្រសួងផែនការ នៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០១៣ ហើយនឹងស្នើទៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីការអនុញ្ញាត[១៥]។ សេចក្តីព្រាងនេះ ផ្តោតទៅលើវិស័យសំខាន់ចំនួន ៦ គឺ កសិកម្ម វប្បធម៌ អប់រំ សុខាភិបាល ទេសចរណ៍ ឧស្សាហកម្ម និងពាណិជ្ជកម្ម ដែលមានគោលបំណងចម្បងចំនួនបួនធំៗ ពោលគឺធ្វើឱ្យប្រសើរឡើងដល់លទ្ធភាពនិងសមត្ថភាព គោលនយោបាយសេដ្ឋកិច្ច ចំណេះដឹង និងច្បាប់ដែលពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញា ដើម្បីបំពេញតម្រូវការសេដ្ឋកិច្ច និងសង្គមកម្ពុជា[១៦]។ នាយកដ្ឋានបានរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលរួមមាន ១៧ ជំពូក និងចែកចេញជា ៤១ មាត្រា ហើយបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៣ និងប្រកាសឱ្យប្រើនៅថ្ងៃទី ២០ ខែមករា ឆ្នាំ២០១៤[១៧]។ ក្រៅពីនេះ នាយកដ្ឋានកម្មសិទ្ធិបញ្ញាបានរៀបចំអនុក្រឹត្យស្តីពីវិធានការណ៍តាមព្រំដែន ដែលនឹងត្រូវព្រាងឡើងក្នុងឆ្នាំ២០១៤-២០១៥[១៨] ដើម្បីចែងលម្អិតអំពីនីតិអនុវត្តទម្រង់ការទប់ស្កាត់ការរំលោភបំពានកម្មសិទ្ធិបញ្ញាតាមព្រំដែន ដោយអនុញ្ញាតឱ្យម្ចាស់ម៉ាកដែលបានចុះបញ្ជីហើយ អាចធ្វើពាក្យ

[១៣] ក្រសួងពាណិជ្ជ, សេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០១៣, ២៥ មេសា ២០១៤។

[១៤] ក្រសួងពាណិជ្ជ, សេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០១៣, ២៥ មេសា ២០១៤។

[១៥] ពិន សុវិចិត្រ, វគ្គបណ្តុះបណ្តាលសម្រាប់ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក។

[១៦] ក្រសួងពាណិជ្ជ, សេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០១៣,២៥ មេសា ២០១៤។

[១៧] អង្គការកម្មសិទ្ធិពិភពលោក, វគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញា,០៥-១៥ វិច្ឆិកា ២០១២។

[១៨] ពិន សុវិចិត្រ, វគ្គបណ្តុះបណ្តាលសម្រាប់ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក។

បណ្តឹងទៅរដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ ឱ្យព្យួរទុកនូវការធ្វើបែបបទទំនិញណាដែលសង្ស័យថា មានម៉ាកក្លែងក្លាយ ដោយបង្ហាញនូវភ័ស្តុតាងច្បាស់លាស់ថា ខ្លួនជាម្ចាស់នៃម៉ាកដែលបានចុះបញ្ជី[១៩]។ នាយកដ្ឋានក៏បានធ្វើការសហការពិនិត្យផលចំណេញ និងផលប៉ះពាល់ក្នុងការចូល ពិធិសារទីក្រុងម៉ាដ្រិត ស្តីពីការចុះបញ្ជីម៉ាកជាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជានឹងត្រូវចូលជាសមាជិកនៅឆ្នាំ២០១៥ ក៏ដូចជាសន្ធិសញ្ញាស្តីពីម៉ាកផងដែរ។ នាយកដ្ឋានកម្មសិទ្ធិបញ្ញា បានរៀបចំសេចក្តីព្រាងច្បាប់ស្តីការសម្ងាត់ពាណិជ្ជកម្ម និងព័ត៌មានមិនទម្លាយចេញ ដែលត្រូវពិភាក្សាជាមួយអង្គការ WIPO នៅក្នុងខែធ្នូ ឆ្នាំ២០១៨ ដោយក្នុងនោះនាយកដ្ឋានកម្មសិទ្ធិបញ្ញា បានធ្វើការរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីនីតិវិធីអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា[២០]។ បន្ថែមពីនេះទៀត នាយកដ្ឋានកម្មសិទ្ធិបញ្ញា បានបន្តសិក្សាស្រាវជ្រាវ ក្នុងការរៀបចំសេចក្តីព្រាងប្រកាស ស្តីពីក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា Board of Appeal និងសេចក្តីព្រាងប្រកាស ស្តីពីនីតិវិធីនិងការកត់ត្រាអាជ្ញាប័ណ្ណនិងហ្វ្រែនឆាយ[២១] ដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញាឱ្យកាន់តែមានភាពប្រសើរឡើង ដោយមានការចូលរួមសហការជាមួយអង្គភាពពាក់ព័ន្ធដូចជា តុលាការ ព្រះរាជអាជ្ញា ប៉ូលិសសេដ្ឋកិច្ច និងនាយកដ្ឋានទទួលបន្ទុកកម្មសិទ្ធិបញ្ញានានា។

### ៣. ការងារបណ្តុះបណ្តាល

នាយកដ្ឋានកម្មសិទ្ធិបញ្ញា បានធ្វើការៀបចំសិក្ខាសាលា ក៏ដូចជាវគ្គបណ្តុះបណ្តាលមួយចំនួនដែលទាក់ទងនឹងវិស័យកម្មសិទ្ធិបញ្ញា ក្នុងគោលបំណងពង្រឹងបន្ថែម នូវចំណេះដឹងខាងកម្មសិទ្ធិបញ្ញាដល់មន្ត្រីពាក់ព័ន្ធ ស្ថាប័នជំនាញដទៃ និងសិស្សានុសិស្សឱ្យ មានការយល់ដឹងផ្នែកកម្មសិទ្ធិបញ្ញា ឱ្យកាន់តែទូលំទូលាយផងដែរ។ ដោយជាក់ស្តែងនាយកដ្ឋានកម្មសិទ្ធិបញ្ញាបានបញ្ជូនសិក្ខាកាមទៅសិក្សា វគ្គបណ្តុះបណ្តាលនៅបរទេសចំនួន ៧១ ដង ដែលស្មើនឹង ៤៨ នាក់ នឹងធ្វើការ បណ្តុះបណ្តាលនៅក្នុងប្រទេសចំនួន ១០ ដង ដែលមានសិក្ខាកាមចំនួន ៥៧៤ នាក់។ នាកយដ្ឋានក៏បានបណ្តុះបណ្តាលនៅតាមសាកលវិទ្យាល័យចំនួន ០៦ សាកលវិទ្យាល័យ ហើយមាននិស្សិតចូលរួមប្រហែល ១៦០០ នាក់។ ជាពិសេស នាយកដ្ឋានបានរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់ពង្រឹងសមត្ថភាពខាងកម្មសិទ្ធិបញ្ញាដល់ចៅក្រម និងមន្ត្រីជាន់ខ្ពស់នៃសាលាភូមិន្ទរដ្ឋបាល ហើយនាយកដ្ឋានកម្មសិទ្ធិបញ្ញា ក៏បានរៀបចំសិក្ខាសាលា សម្រាប់ភ្នាក់ងារតំណាងស្របច្បាប់ខាងម៉ាកបានពីរដងផងដែរ[២២]។

---

[១៩] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខនស/រកម/០២០២/២០០៦, ០៦ ធ្នូ ២០០១, មាត្រា៣៥។

[២០] ក្រសួងពាណិជ្ជ, សេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០១៨-២០១៩។

[២១] ក្រសួងពាណិជ្ជ, សេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០១៨-២០១៩។

[២២] ក្រសួងពាណិជ្ជ, សេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០១៣, ២៥ មេសា ២០១៤។

## ៤. ការចារចុះបញ្ជី

ទន្ទឹមនឹងនេះដែរ លទ្ធផលដែលនាយកដ្ឋានកម្មសិទ្ធិបញ្ញាសម្រេចបាននៅក្នុងឆ្នាំ២០១៨ នោះគឺ ទទួលបានពាក្យស្នើសុំចុះបញ្ជីម៉ាកសរុបចំនួន ៥៩៤២ ម៉ាក ក្នុងនោះម៉ាកក្នុងស្រុកមានចំនួន ២២៤០ ម៉ាក និងក្រៅស្រុកមានចំនួន ៣៥០២ ម៉ាក។ ក្នុងចំនោមពាក្យស្នើសុំទាំងអស់នោះ នាយកដ្ឋានកម្មសិទ្ធិបញ្ញាបានឯកភាពចុះបញ្ជីជូនអចិតិជនសរុបចំនួន ៤១៨៦ ម៉ាក ដែលក្នុងនោះម៉ាកក្នុងស្រុកមានចំនួន ១៤៨៤ ម៉ាក និងម៉ាកក្រៅស្រុកចំនួន ២៧០២ ម៉ាក[២៣]។

ក្រោយពីបានចុះបញ្ជី នាយកដ្ឋានកម្មសិទ្ធិបញ្ញាក៏បានទទួលពាក្យស្នើសុំលុបម៉ាកចំនួន ៦៤ ម៉ាក នៅក្នុងឆ្នាំ ២០១៧-២០១៨។ ហើយនាយកដ្ឋានក៏បានធ្វើការលុបចោលម៉ាកចេញពីបញ្ជីម៉ាកសរុបចំនួន ៣០ ម៉ាក ក្រៅពីនេះ នាយកដ្ឋានបានទទួលពាក្យស្នើសុំទប់ស្កាត់ការបំពានកម្មសិទ្ធិបញ្ញាចំនួន ១៤ ម៉ាក ហើយនឹងបានធ្វើការសម្រុះសម្រួលវិវាទចំនួន ១០ ម៉ាកនៅក្នុងឆ្នាំ២០១៨[២៤]។

## កថាភាគទី២៖ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

វិស័យឧស្សាហកម្ម និងសិប្បកម្មពីមុនស្ថិតក្នុងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែតាមរយៈព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រសួងឧស្សាហកម្មនិងសិប្បកម្ម វិស័យនេះត្រូវស្ថិតនៅក្នុងក្រសួងថ្មី ព្រោះក្រសួងឧស្សាហកម្ម និងសិប្បកម្មជាស្ថាប័នចំណុះរាជរដ្ឋាភិបាលកម្ពុជា ដែលមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យឧស្សាហកម្ម និងសិប្បកម្មនៃព្រះរាជាណាចក្រកម្ពុជា[២៥]។ ក្រសួងឧស្សាហកម្ម និងសិប្បកម្មជាស្ថាប័នដែលទទួលបន្ទុកលើកិច្ចការ ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ គំនូរឧស្សាហកម្ម គំនូបង្ហាញនៃសៀគ្វីបង្រួម និងកិច្ចការពារប្រភេទរុក្ខជាតិថ្មី តាមរយៈច្បាប់ស្តីអំពីពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ[២៦]។ រាល់ការងារទាំងឡាយដែលទាក់ទងទៅនឹងវិស័យកម្មសិទ្ធិឧស្សាហកម្មក្រសួងបានប្រគល់ភារកិច្ចទៅឱ្យនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ដែលស្ថិតក្នុងអគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

---

[២៣] ក្រសួងពាណិជ្ជ, សេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០១៨-២០១៩។

[២៤] ក្រសួងពាណិជ្ជ, សេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០១៨-២០១៩។

[២៥] ព្រះរាជក្រមស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម, លេខ នស/រកម/១២១៣/០១៨, ០៩ ធ្នូ ២០១៣, មាត្រា២។

[២៦] ង៉ែត វិបុល, "ការត្រួតពិនិត្យលើខ្លឹមសារនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម និងបញ្ហាប្រឈម", (បទបង្ហាញនៅក្នុងសិក្ខាសាលាកម្មសិទ្ធិបញ្ញា, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២៤ មេសា ២០០៨)។

## ១. នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ដោយមានការិយាល័យចំណុះចំនួន៥ការិយាល័យ និងមជ្ឈមណ្ឌល១[២៧] ដោយក្នុងនោះមានដូចជា ការិយាល័យរដ្ឋបាល ការិយាល័យប្រកាសនីយបត្រតក្កកម្ម ការិយាល័យគំនូរឧស្សាហកម្ម ការិយាល័យសិទ្ធិអ្នកបង្កាត់ពូជដំណាំ ការិយាល័យដោះស្រាយវិវាទនិងសហប្រតិបត្តិការ និងមជ្ឈមណ្ឌលការច្នៃប្រឌិតនិងបង្កើតថ្មី[២៨]។

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មមានតួនាទី និងភារកិច្ចមួយចំនួន ដូចទៅនឹងសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្ម លើការងារទាំងឡាយដែលពាក់ព័ន្ធទៅនិងកម្មសិទ្ធិឧស្សាហកម្ម។ ម្យ៉ាងទៀត នាយកដ្ឋាននេះបានរៀបចំនិងអនុវត្តនៅគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ ផែនការក្នុងការពង្រឹងការពារសិទ្ធិ លើកម្មសិទ្ធិឧស្សាហកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម សហការរៀបចំគោលនយោបាយ អំពីការច្នៃប្រឌិតនិងការបង្កើតថ្មី នៅក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍបច្ចេកវិទ្យា និងគ្រប់គ្រងមណ្ឌលច្នៃប្រឌិត មណ្ឌលបង្កើតតក្កកម្ម មណ្ឌលស្រាវជ្រាវនិងពិនិត្យកម្មសិទ្ធិឧស្សាហកម្ម មណ្ឌលផ្សព្វផ្សាយ និងបណ្តុះបណ្តាលកម្មសិទ្ធិឧស្សាហកម្ម។ ក្រៅពីនេះ នាយកដ្ឋានក៏បានធ្វើការផ្សព្វផ្សាយតាមរយៈព្រឹត្តិបត្រផ្លូវការ ក៏ដូចជាតាមមធ្យោបាយផ្សេងៗ ក្នុងការប្រើប្រាស់ព័ត៌មានស្តីពីកម្មសិទ្ធិឧស្សាហកម្ម ធ្វើជាឧបករណ៍ដើម្បីជំរុញការច្នៃប្រឌិតថ្មី ព្រមទាំងធ្វើការសម្របសម្រួល ដោះស្រាយវិវាទពាក់ព័ន្ធនឹងកម្មសិទ្ធិឧស្សាហកម្ម និងធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ និងអង្គការអន្តរជាតិនានា ដែលជាដៃគូអភិវឌ្ឍលើការងារកម្មសិទ្ធិឧស្សាហកម្ម។ ជាពិសេស នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មធ្វើការបូកសរុបរបាយការណ៍ វាយតម្លៃលទ្ធផលការងារ និងអភិវឌ្ឍវិស័យកម្មសិទ្ធិឧស្សាហកម្ម ព្រមទាំងទទួល អនុវត្តភារកិច្ចផ្សេងៗ ដែលប្រធានស្ថាប័នប្រគល់ជូន[២៩]។ សមិទ្ធផលចម្បងៗ របស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មមានដូចជា ការរៀបចំច្បាប់ និងបទប្បញ្ញត្តិនានា ការងារបណ្តុះបណ្តាល និងការងារចុះបញ្ជី។

## ២. ការរៀបចំច្បាប់ និងបទប្បញ្ញត្តិ

នៅក្នុងការងារនៃការកសាងច្បាប់ នាយកដ្ឋានបានរៀបចំស្តីពីប្រកាសនីយបត្រតក្កកម្ម គំនូរឧស្សាហកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ (ច្បាប់ប្រកាសនីយបត្រតក្កកម្ម) ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី០២ ខែមករា ឆ្នាំ២០០៣។ នៅក្នុងថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៦ នាយកដ្ឋានបានដាក់ឱ្យប្រើប្រាស់នូវប្រកាសស្តីពីការអនុវត្តច្បាប់ប្រកាសនីយបត្រតក្កកម្ម។ ក្រៅពីនេះ នាយកដ្ឋានបានរៀបចំច្បាប់ស្តីពីពូជដំណាំ រួមទាំង

---

[២៧] ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម, លេខ៤៥១ប្រក, ២៨ ឧសភា ២០១៤, ប្រការ៥។

[២៨] យោងតាមអង្គការលេខរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ដែលមានភ្ជាប់ឧបសម្ព័ន្ធទី២។

[២៩] ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម, លេខ៤៥១ប្រក, ២៨ ឧសភា ២០១៤, ប្រការ៣។

សិទ្ធិអ្នកបង្កាត់ពូជដំណាំ ត្រូវបានប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៨[៣០]។ ដោយនៅក្នុងឆ្នាំ ២០១៣ នាយកដ្ឋានបានរៀបចំសេចក្តីព្រាងសេចក្តីសម្រេច ស្តីពីការអនុវត្តសិទ្ធិអ្នកបង្កាត់ពូជដំណាំ ព្រមទាំងបានបកប្រែនិងបោះពុម្ពសៀវភៅចំនួនពីរគឺៈ

– ទី១. អនុសញ្ញាអន្តរជាតិ ស្តីពីកិច្ចការពារពូជថ្មីនៃដំណាំ

– ទី២. មគ្គុទេសសម្រាប់ការរៀបចំច្បាប់ ផ្អែកលើច្បាប់ឆ្នាំ១៩៩១ នៃអនុសញ្ញាសហភាពនៃពូជថ្មី នៃដំណាំ។ ជាពិសេសនេះទៅទៀត នាយកដ្ឋានបានបញ្ជូលច្បាប់ស្តីពីគំនូរបង្ហាញនូវសៀគ្វីបង្រួម ទៅអង្គការកម្មសិទ្ធិបញ្ញាពិភពលោកដើម្បីពិនិត្យរួចហើយ តែពុំទាន់បានទទួលការឆ្លើយតបមកវិញ[៣១]។

នៅក្នុងឆ្នាំ២០១៤ នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មបានធ្វើការរៀបចំកែសម្រួល ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មជាថ្មីវិញ រៀបចំកែសម្រួលនីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម និងនីតិវិធីផ្តល់ប្រកាសនីយបត្រគក្កកម្មជាថ្មីឱ្យស្របតាមអនុក្រឹត្យស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្រៅពីនេះទៅទៀត នាយកដ្ឋានបានធ្វើការពិនិត្យ សេចក្តីព្រាងប្រកាសអនុវត្តច្បាប់ ស្តីពីសិទ្ធិអ្នកបង្កាត់ពូជដំណាំ ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមទាំងប្រកាស ស្តីពីនីតិវិធីចុះបញ្ជីឧស្សាហកម្ម និងធ្វើកែប្រែទម្រង់ដាក់ពាក្យស្នើសុំផងដែរ។ ជាពិសេស នាយកដ្ឋាននឹងធ្វើការជ្រើសរើសមន្ត្រី៥នាក់បន្ថែមដើម្បីសម្រួលការងារក្នុងការចូលជាសមាជិកទីក្រុងផែនការ៥ឆ្នាំទៅមុខ ដើម្បីបង្កើនប្រសិទ្ធភាពឱ្យកាន់តែប្រសើរ និងឆាប់រហ័សក្នុងការចុះគំនូរឧស្សាហកម្ម[៣២]។ ហើយក្នុងនោះផងដែរ នាយកដ្ឋានបានកំពុងត្រួតពិនិត្យឯកសារ និងពិនិត្យលក្ខណៈបច្ចេកទេសគំនូរឧស្សាហកម្ម ដើម្បីសុំគោលការណ៍ចុះបញ្ជី។

## ៣. ការងារបណ្តុះបណ្តាល

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មបានបណ្តុះបណ្តាល និងជំរុញគាំទ្ររោងចក្រនិងសហគ្រាសធុនតូច និងមធ្យមឱ្យចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានាដូចជា សិក្ខាសាលាស្តីពីសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣ នៅទីស្តីការក្រសួងពាណិជ្ជកម្ម[៣៣]។ ជាក់ស្តែង ការបណ្តុះបណ្តាលក្នុងប្រទេសមានដូចជា វគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ និងគ្រប់គ្រង កាលពីថ្ងៃទី២៥ដល់២៩ ខែមីនា ឆ្នាំ២០១៣។ សិក្ខាសាលាស្តីពីការលើកម្ពស់នៃការបង្កើតម៉ាក កិច្ចការពារ និង

[៣០] ពិន សុវិចិត្រ, វគ្គបណ្តុះបណ្តាលសម្រាប់ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក។

[៣១] ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, របាយការណ៍ការសកម្មភាពប្រចាំឆ្នាំចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៣,១។

[៣២] ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, របាយការណ៍ការសកម្មភាពប្រចាំឆ្នាំចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៣,៥។

[៣៣] ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, របាយការណ៍ការសកម្មភាពប្រចាំឆ្នាំចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៣,៥។

ការគ្រប់គ្រង កាលថ្ងៃទី០៧ដល់១០ ខែតុលា ឆ្នាំ២០១៣ នៅប្រទេសម៉ាឡេស៊ីព្រមទាំងសិក្ខាសាលាមួយចំនួនផ្សេងទៀត[៣៤]។

ដោយឡែកនៅក្នុងឆ្នាំ ២០១៦ បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីជំនាញត្រួតពិនិត្យជញ្ជីងមិនស្វ័យប្រវត្តិ និងឧបករណ៍បែងចែកតេលសិលា ជូនដល់មន្ត្រីត្រួតពិនិត្យការងារមាត្រាសាស្ត្រ ដែលមានសិក្ខាកាមចូលរួមចំនួន៧៩នាក់ រួមមាន៖ មន្ត្រីក្រសួងចំនួន ២២ រូបនិងមន្ត្រី រាជធានី ខេត្តចំនួន ៥៧ រូប។ ជាពិសេស នៅថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០១៨ បានរៀបចំបើកវគ្គបណ្តុះបណ្តាល ស្តីពីសុវត្ថិភាពឧស្សាហកម្ម ដែលវគ្គបណ្តុះបណ្តាលនេះធ្វើឡើងក្នុងគោលបំណង ចែករំលែកចំណេះដឹង និងបទពិសោធន៍ ស្តីពីកាគ្រប់គ្រង ការថែទាំ ការត្រួតពិនិត្យ និងផ្សព្វផ្សាយពីបទបញ្ញត្តិនានា នៃការគ្រប់គ្រងគ្រឿងចក្រគ្រឿងម៉ាស៊ីន ដែលមានហានិភ័យក្នុងរោងចក្រ សិប្បកម្ម ជូនដល់វិស័យឯកជន ហើយវគ្គបណ្តុះបណ្តាលនេះ មានសិក្ខាកាមចូលរួមចំនួនសរុប ៩៩ រូប ដែលមកពីរោងចក្រចំនួន ២៣ នៅរាជធានីភ្នំពេញ និងបណ្តាខេត្តនានា ដែលធ្វើឡើងនៅក្នុងសាលប្រជុំរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។ នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៨ បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីសុវត្ថិភាពឧស្សាហកម្មលើកទី១៣ ហើយវគ្គបណ្តុះបណ្តាលនេះ មានសិក្ខាកាមចូលរួមចំនួនសរុប ២៨៦ រូប ដែលមកពីរោងចក្រចំនួន ៧០ នៅរាជធានីភ្នំពេញ និងបណ្តាខេត្តនានា ដែលធ្វើឡើងនៅក្នុងសាលប្រជុំរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

## ៤. ការខាចុះបញ្ជី

នៅក្នុងការងារចុះបញ្ជី ផ្នែកប្រកាសនីយបត្រតក្កកម្ម និង វិញ្ញាបនបត្រម៉ូដែល មានអត្ថប្រយោជន៍ នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម បានទទួលសំណុំលិខិតស្នើចំនួន ៨២ លិខិត នៅក្នុងឆ្នាំ ២០១៣ ដែលមានសំណុំលិខិតប្រកាសនីយបត្រតក្កកម្មចំនួន ៧១ ដោយនៅក្នុងស្រុកមានចំនួន ០១ និងក្រៅស្រុកមានចំនួន ៧៤ ហើយនិងសំណុំលិខិតវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ចំនួន ០៧ ក៏ប៉ុន្តែនាយកដ្ឋានមិនទាន់បានផ្តល់ការចុះបញ្ជីឱ្យសំណុំលិខិតទាំង ៨៤ នេះនៅឡើយទេ[៣៥]។ រីឯគំនូរឧស្សាហកម្មវិញ នាយកដ្ឋានបានទទួលពាក្យស្នើសុំចុះបញ្ជីសរុបចំនួន ១២៥ នៅក្នុងឆ្នាំ២០១៣ ដែលក្នុងនោះមានពាក្យសុំថ្មីចំនួន ៨៨ និងពាក្យសុំចុះសារឡើយវិញចំនួន ៣៧ ។ ជាលទ្ធផល នាយកដ្ឋានបានផ្តល់ការចុះបញ្ជី គំនូរឧស្សាហកម្មសរុបចំនួន ៩៨[៣៦]។

[៣៤] ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, របាយការណ៍ការសកម្មភាពប្រចាំឆ្នាំចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៣,៦។

[៣៥] ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, របាយការណ៍ការសកម្មភាពប្រចាំឆ្នាំចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៣,២។

[៣៦] ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, របាយការណ៍ការសកម្មភាពប្រចាំឆ្នាំចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៣,៣។

## កថាភាគទី៣៖ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រង លើវិស័យវប្បធម៌ និងវិចិត្រសិល្បៈនៃព្រះរាជាណាចក្រកម្ពុជា[៣៧] និងជាអ្នកប្រតិបត្តិនូវនយោបាយការពារ ថែរក្សា លើកតម្លៃវប្បធម៌ ជំនឿទំនៀមទម្លាប់ ប្រពៃណីរបស់សង្គមជាតិ បំផុសការបង្កើតថ្មីស្នាដៃ ផ្សព្វផ្សាយនិងអភិវឌ្ឍន៍សកម្មភាពវប្បធម៌ លើកតម្លៃបេតិកភណ្ឌវប្បធម៌ និងសម្បត្តិវប្បធម៌ជាតិ[៣៨]។ ដោយសារក្រសួងនេះទទួលបន្ទុកទាក់ទងនឹងវិស័យវប្បធម៌ ទាំងជាអ្នកបំផុសការបង្កើតថ្មីស្នាដៃ ទើបក្រសួងបានទទួលភារកិច្ចខាងការការពារកម្មសិទ្ធិបញ្ញា លើសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលដែល ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល[៣៩]។

### ១. នាយកដ្ឋានកម្មសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល គឺជាអង្គភាពស្ថិតនៅក្រោមឱវាទអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់[៤០] ព្រមទាំងមានការិយាល័យចំនួន ៥ ការិយាល័យ[៤១] គឺការិល័យរដ្ឋបាល ការិយាល័យការពារស្នាដៃ ការិយាល័យស្រាវជ្រាវនិងអភិវឌ្ឍ ការិយាល័យអប់រំផ្សព្វផ្សាយ និងការិយាល័យអង្គភាពគ្រប់គ្រងសិទ្ធិរួម[៤២]។ នាយកដ្ឋានមួយនេះ មានភារកិច្ចក្នុងការគ្រប់គ្រង សម្របសម្រួលការងារជាមួយអង្គភាពគ្រប់គ្រងសិទ្ធិរួម និងធ្វើឱ្យប្រសើរនូវការអនុវត្តច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។ នាយកដ្ឋានក៏បានធ្វើទំនាក់ទំនងជាមួយអង្គភាពសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនៅក្រៅប្រទេស ព្រមទាំងធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់នាយកដ្ឋានផងដែរ។ ក្រៅពីនេះ នាកយដ្ឋានជាអ្នកទទួលចុះបញ្ជី ការពារស្នាដៃ សិក្សាស្រាវជ្រាវ អប់រំ និងផ្សព្វផ្សាយសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ក៏ដូចជាលើកកម្មវិធី និងអនុវត្តនយោបាយសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ក្នុងគោលបំណងជំរុញការលើកទឹកចិត្ត ក្នុងការការពារ

---

[៣៧] ព្រះរាជក្រមស្តីពីការបង្កើតក្រសួងវប្បធមិ និងវិចិត្រសិល្បៈ,លេខ នស/រកម/០១៩៦/០២,២៤ មករា ១៩៩៦, មាត្រា២។

[៣៨] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធមិ និងវិចិត្រសិល្បៈ, លេខ២២៤ អនក្រ/បក. ១៩ មីនា ២០០៧, មាត្រា៣។

[៣៩] ប្រកាសស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, លេខ១៦៨បក្រ,០៦ សីហា ២០០៧, ប្រកាស១។

[៤០] ប្រកាសស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, លេខ១៦៨បក្រ,០៦ សីហា ២០០៧, ប្រកាស៣។

[៤១] ប្រកាសស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, លេខ១៦៨បក្រ,០៦ សីហា ២០០៧, ប្រកាស៤។

[៤២] យោងតាមអង្គការលេខរបស់នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដែលភ្ជាប់ក្នុងឧបសម្ព័ន្ធទី៣។

ស្នាដៃ និងការបង្កើតផលិតផលថ្មីខាងវិស័យវប្បធម៌។ ជាពិសេស នាយកដ្ឋានត្រូវបានទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន[៤៣]។

## ២. ការរៀបចំច្បាប់ និងបទប្បញ្ញត្តិ

នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល បានធ្វើការរៀបចំច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ប្រកាសលេខ៦០ ប្រកវវស ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៣ ស្តីពីការបញ្ឈប់ជាបន្ទាន់រាល់សកម្មភាព ដែលរំលោភសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ប្រកាសអន្តរក្រសួងលេខ៦៤៩ សហវ ប្រក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកំណត់កម្រៃសុំសិទ្ធិបង្កើតផលិតផលវប្បធម៌សម្រាប់ប្រកបអាជីវកម្មលើស្នាដៃអ្នកនិពន្ធ អក្សរសាស្ត្រ សិល្បៈ និងតូរ្យតន្ត្រី ដែលគ្មានអ្នកទទួលមរតក ឬគ្មានមរតកសាសន៍ ហើយនិងប្រកាសអន្តរក្រសួងលេខ ៤៦៧ សហវ ប្រក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកំណត់កម្រៃអាជ្ញាប័ណ្ណ ភាពយន្ត និងវិឌីអូ។

ម្យ៉ាងវិញទៀត នាយកដ្ឋានបានធ្វើការរៀបចំតាក់តែងសេចក្តីព្រាងអនុក្រឹត្យស្តីពីអង្គភាពគ្រប់គ្រងសិទ្ធិរួមនៅក្នុងឆ្នាំ២០០៨ ដោយមាន ៨ ជំពូក និង ២៧ មាត្រា ដែលត្រូវបានបញ្ចប់ការពិភាក្សាជាមួយក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការការគណៈរដ្ឋមន្ត្រី។ នៅក្នុងឆ្នាំ២០១១ នាយកដ្ឋានបានរៀបចំប្រកាសលេខ ២២០ ប្រក វវស ស្តីពីការគ្រប់គ្រងអាជីវកម្ម និងងសេវាកម្ម លក់ ជួល ផលិតផលភាពយន្ត និងវីឌីអូ។ ដោយឡែកនៅក្នុងឆ្នាំ២០១២ នាយកដ្ឋានបានបន្តធ្វើការរៀបចំប្រកាសលេខ ១៥០ ស្តីពីការគ្រប់គ្រងអាជីវកម្មឌីអុបទិក និងឧបករណ៍ថតចម្លង និងបានរៀបចំប្រកាសលេខ ១៥១ ស្តីពីការផ្តល់សេវាកម្មគ្រប់គ្រងអាជីវកម្មសេវាថតចម្លង[៤៤]។ ជាងនេះទៅទៀត នៅក្នុងឆ្នាំ២០១៥ នាយកដ្ឋានបានរៀបចំប្រកាស ស្តីពីអង្គភាពគ្រប់គ្រងសិទ្ធិរួម និងបានរៀបចំធ្វើការកែសម្រួលលើប្រកាសរួម ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈលើវិស័យសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល[៤៥]។

## ៣. ការងារបណ្តុះបណ្តាល

នៅក្នុងចន្លោះឆ្នាំ ២០០៣ ដល់ឆ្នាំ ២០០៦ នាយកដ្ឋានបានធ្វើការផ្សព្វផ្សាយច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងតាមបណ្តាខេត្ត ក្រុងចំនួន ១៧ កន្លែង ដោយក្នុង

---

[៤៣] ប្រកាសស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, លេខ១៦៨បក្រ,០៦ សីហា ២០០៧, ប្រកាស២។

[៤៤] នាយកដ្ឋាននីតិកម្មនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, កម្រងបទដ្ឋានគតិយុត្តក្នុងវិស័យវប្បធម៌ និងវិចិត្រសិល្បៈ (ភ្នំពេញ៖ នាយកដ្ឋាននីតិកម្មនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ២០១២។

[៤៥] ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, របាយការណ៍លទ្ធផលការងារវប្បធម៌និងវិចិត្រសិល្បៈប្រចាំឆ្នាំ២០១៥, (១២-០១-២០១៦)។

នោះមានការចូលរួមពីសំណាក់មន្ត្រីរាជការចំនួន ១៧៨០ នាក់ សាធារណៈជនចំនួន ១០៦០ នាក់ ។ នៅឆ្នាំ ២០០៦ នាយកដ្ឋានបានធ្វើការអប់រំ ដល់និស្សិតបរិញ្ញាបត្រចំនួន ៤៩ នាក់ ដែលមកពីមហាវិទ្យាល័យបុរាណវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៧៣ នាក់ ដែលមកពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

នៅរាជធានីភ្នំពេញថ្ងៃទី ០៨ ដល់ថ្ងៃទី ១០ ខែតុលា ឆ្នាំ២០០៨ នាយកដ្ឋានបានធ្វើការសហការជាមួយមជ្ឈមណ្ឌលវប្បធម៌អាស៊ីប៉ាស៊ីហ្វិក សម្រាប់អង្គការយូណេស្កូ បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលថ្នាក់ជាតិស្តីពីចំណេះដឹងសិទ្ធិអ្នកនិពន្ធចំនួន ០១ លើក។ ក្នុងឆ្នាំ២០០៩ នាយកដ្ឋានបានធ្វើការសហការជាមួយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងសាធារណៈរដ្ឋកូរ៉េ បានរៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការកសាងចំណេះដឹងសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលចំនួន ០១ លើក ហើយនិងក្នុងឆ្នាំ២០១០ នាយកដ្ឋានបានធ្វើការសហការជាមួយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក បានរៀបចំសិក្ខាសាលា ស្តីពីអង្គភាពគ្រប់គ្រងសិទ្ធិរួម និងសិក្ខាសាលាស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលចំនួន ០១ លើក។

នៅក្នុងឆ្នាំ ២០១១ នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល បានធ្វើការរៀបចំសិក្ខាសាលាស្តីពីអង្គភាពគ្រប់គ្រងសិទ្ធិរួមចំនួន ០១ លើក។ នៅឆ្នាំ ២០១២ នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល បានរៀបចំសិក្ខាសាលាចំនួន ០១ លើក ដែលមានសិក្ខាកាមចំនួន ១២០ នាក់ លើប្រធានបទ "សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល" ដោយមានការឧបត្ថម្ភពីអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។ នៅឆ្នាំ២០១៣ នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល បានសហការជាមួយក្រសួងវប្បធម៌ កីឡា និងទេសចរណ៍ នៃសាធារណៈរដ្ឋកូរ៉េ និងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក បានរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។ នៅឆ្នាំ ២០១៤ នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល បានរៀចំសិក្ខាសាលាថ្នាក់ជាតិមួយ ស្តីពីសិទ្ធិអ្នកនិពន្ធ ការច្នៃប្រឌិត និងការអភិវឌ្ឍ ដែលធ្វើនៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ នៅឆ្នាំ ២០១៥ នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ក៏បានសហការជាមួយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក បានរៀបចំសិក្ខាសាលាចំនួន ០២ គឺសិក្ខាសាលាថ្នាក់ជាតិ ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល និងសិក្ខាសាលាថ្នាក់អនុតំបន់ ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។ ចំណែកឯការងារបណ្តុះបណ្តាលក្រៅប្រទេស ក្រសួងបានបញ្ជូនសិក្ខាកាមចំនួន ០៧ នាក់ទៅចូលរួមវគ្គបណ្តុះបណ្តាលចំនួន ០៦ លើកផងដែរ[៦]។

[៦] ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, របាយការណ៍សកម្មភាពការងាររបស់នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, ២០១៣។

## ៤. ការខារចុះបញ្ជី

នៅក្នុងឆមាសទី១ ដើមឆ្នាំ ២០០៨ នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល បានធ្វើការចុះបញ្ជីការពារស្នាដៃចំនួន ០២ ស្នាដៃ ការសុំសិទ្ធិធ្វើអាជីវកម្ម និងការអនុញ្ញាតសិទ្ធិ ធ្វើអាជីវកម្មលើស្នាដៃអក្សរសាស្ត្រ សិល្បៈ និងតូរ្យតន្ត្រី គ្មានអ្នកទទួលមរតក ឬគ្មានមរតកសាសន៍ មានចំនួន ០៦ ផលិតកម្ម ស្មើនឹង ២៥១ បទចម្រៀង និងរឿងចំនួន០១[៤៧]។ នៅឆ្នាំ ២០១១ នាយកដ្ឋានបានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ចេញលិខិតបញ្ជាក់ការការពារស្នាដៃសរុបចំនួន ៤៦ ស្នាដៃ និងបានចេញលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មលើស្នាដៃគ្មានមរតកសាសន៍នូវបទចម្រៀងចំនួន ១៨០ បទ និងស្នាដៃអក្សរសាស្ត្រចំនួន០១[៤៨]។ នៅក្នុងឆ្នាំ ២០១២ នាយកដ្ឋានបានទទួលពាក្យស្នើសុំចុះបញ្ជីការពារស្នាដៃចំនួន ២១ ស្នាដៃហើយនាយកដ្ឋានក៏បានអនុញ្ញាតចុះបញ្ជីឱ្យចំនួន ២១ ស្នាដៃ។ នាយកដ្ឋានបានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ទទួលពាក្យស្នើសុំសិទ្ធិធ្វើអាជីវកម្មលើស្នាដៃគ្មានមរតកសាសន៍ចំនួន ១៥៨ បទចម្រៀង ហើយនាយកដ្ឋានអនុញ្ញាតចុះបញ្ជីលើសិទ្ធិធ្វើអាជីវកម្មលើស្នាដៃគ្មានមរតកសាសន៍ចំនួន ១៥៨ បទចម្រៀង។

នៅក្នុងឆ្នាំ ២០១៣ នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល បានទទួលពាក្យស្នើសុំចុះបញ្ជីការពារស្នាដៃចំនួន ៨៤ ស្នាដៃ ហើយនាយកដ្ឋានក៏អនុញ្ញាតចុះបញ្ជីឱ្យចំនួន៨៤ស្នាដៃ។ ក្រៅពីនេះ នាយកដ្ឋានក៏បានទទួលពាក្យស្នើសុំសិទ្ធិធ្វើអាជីវកម្ម លើស្នាដៃគ្មានមរតកសាសន៍ចំនួន ២៩ ពាក្យសុំ ហើយនាយកដ្ឋានអនុញ្ញាតចុះបញ្ជីលើ សិទ្ធិធ្វើអាជីវកម្មលើស្នាដៃគ្មានមរតកសាសន៍ដល់អ្នកស្នើសុំទាំងអស់ ដែលស្មើនឹង ៣៨៣ បទចម្រៀង។ លើសពីនេះ នាកយដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល បានទទួលពាក្យស្នើសុំក្នុងការបោះពុម្ពផ្សាយស្នាដៃចំនួន ០៨ ហើយក៏អនុញ្ញាតឱ្យទាំង ០៨ ស្នាដៃនោះ។ នៅក្នុងឆ្នាំ ២០១៤ នាយកដ្ឋានបានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ចេញលិខិតអនុញ្ញាតធ្វើអាជីវកម្ម លើស្នាដៃគ្មានអ្នកទទួលមរតកសាសន៍នូវចម្រៀងចំនួន ៨៤ បទ និងចេញលិខិតអនុញ្ញាតបោះពុម្ពសៀវភៅប្រលោមលោកចំនួន ០៩ ស្នាដៃ ហើយនិងលិខិតបញ្ជាក់ការចុះបញ្ជីការពារស្នាដៃចំនួន ៤២ ស្នាដៃ[៤៩]។ នៅឆ្នាំ ២០១៥ នាយកដ្ឋានក៏បានផ្តល់សេវាកម្មធ្វើអាជីវកម្មលើស្នាដៃអ្នកទទួលមរតក ឬគ្មានមរតកសាសន៍ចំនួន ១២៧ បទ និងការចុះបញ្ជីការពារស្នាដៃចំនួន៨៩ស្នាដៃ និងការបោះពុម្ពចំនួន ០៧ ស្នាដៃ ហើយនិងការប្រើប្រាស់រូបប្រាសាទអង្គរវត្តចំនួន ០១ ស្នាដៃផងដែរ[៥០]។

[៤៧] ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, របាយការណ៍សកម្មភាពការងាររបស់នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, ២០០៨។

[៤៨] ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, របាយការណ៍សកម្មភាពការងាររបស់នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, ២០១១។

[៤៩] ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, របាយការណ៍ ស្តីពី លទ្ធផលការងារវប្បធម៌ និងវិចិត្រសិល្បៈប្រចាំឆ្នាំ២០១៤, (០៩-០១-២០១៥)។

[៥០] ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, របាយការណ៍ ស្តីពី លទ្ធផលការងារវប្បធម៌ និងវិចិត្រសិល្បៈប្រចាំឆ្នាំ២០១៥, (១២-០១-២០១៦)។

# ជំពូកទី២
# រចនាសម្ព័ន្ធ និងតួនាទីភារកិច្ច

នាយកដ្ឋានកម្មសិទ្ធិបញ្ញា ជាសេនាធិការដ្ឋាននៃក្រសួងពាណិជ្ជកម្ម ក្នុងការសម្របសម្រួលធ្វើការងារផ្សេងពីក្រសួងនានា ដែលទាក់ទងទៅនឹងផ្នែកកម្មសិទ្ធិបញ្ញានៅព្រះរាជាណាចក្រកម្ពុជា។ នាយកដ្ឋានកម្មសិទ្ធិបញ្ញាមួយនេះ ក៏ជាលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញាកម្ពុជា ដោយក្នុងនោះដែរ នាយកដ្ឋានកម្មសិទ្ធិបញ្ញា បានធ្វើការរៀបចំជារចនាសម្ព័ន្ធ និងតួនាទី ភារកិច្ចនានា ដោយបង្កើតឱ្យមាននូវការិយាល័យមួយចំនួន ដើម្បីជួយសម្របសម្រួលការងារផ្នែកកម្មសិទ្ធិបញ្ញាឱ្យមានភាពរីកចម្រើន និងជឿនលឿនដូចបណ្តាប្រទេសដទៃផ្សេងលើសកលលោក។

## ផ្នែកទី១
## នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម

### កថាភាគទី១៖ ការរៀបចំរចនាសម្ព័ន្ធ

នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំដោយផ្ទាល់របស់អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម។ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ[៥១]។ យោងទៅតាមប្រកាសលេខ ២០៦ ព.ណ បណ.បក្រ ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា នាយកដ្ឋានកម្មសិទ្ធិបញ្ញាមានការិយាល័យចំណុះចំនួន ៨ គឺការិយាល័យចុះបញ្ជីម៉ាកពាណិជ្ជកម្ម ការិយាល័យចុះម៉ាកបញ្ជីម៉ាកអន្តរជាតិ ការិយាល័យក្រោយចុះបញ្ជីម៉ាកពាណិជ្ជកម្ម ការិយាល័យម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងព័ត៌មានសម្ងាត់ពាណិជ្ជកម្ម ការិយាល័យវិវាទ ការិយាល័យសហប្រតិបត្តិការ និងកិច្ចការច្បាប់ ការិយាល័យអប់រំ និងចំណេះដឹងសាធារណៈ និងការិយាល័យរដ្ឋបាល និងព័ត៌មានវិទ្យា[៥២]។ ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ[៥៣]។ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ ក្រសួងពាណិជ្ជកម្មត្រូវបានកែសម្រួលពីការិយាល័យរដ្ឋបាល និងព័ត៌វិទ្យា ទៅជាការិយាល័យរដ្ឋបាលទូទៅ[៥៤] និងត្រូវបានបង្កើតការិយាល័យ

[៥១] អង្គការលេខរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១។

[៥២] ប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ,ប្រក.បល.ណ.លេខ២០៦ ព ,២៤ កក្កដា ២០១៤ ,ប្រការ៣។

[៥៣] ប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ,ប្រក.បល.ណ.លេខ២០៦ ព ,២៤ កក្កដា ២០១៤ ,ប្រការ៣ កថាខណ្ឌទី២ ។

[៥៤] ប្រកាសស្តីពីការកែសម្រួលនិងបង្កើតការិយាល័យបន្ថែមចំណុះឱ្យនាយកដ្ឋានកម្មសិទ្ធិបញ្ញា,ប្រក.បល.ណ.លេខ១៧២ ព , ១៦ ឧសភា ២០១៦ ,ប្រការ១។

ស្វ័យប្រវត្តិ និងព័ត៌មានវិទ្យាមួយទៀត[៥៥]។ ក្នុងនោះដែរ ការិយាល័យរដ្ឋបាលទូទៅ និងការិយាល័យស្វ័យប្រវត្តិកម្ម និងព័ត៌មានវិទ្យា ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានចំនួនច្រើនបំផុតពីររូបទៅបួនរូប[៥៦]។ សរុបមក នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម មានការិយាល័យទាំងអស់ចំនួន ០៩ ការិយាល័យ។

## កថាភាគទី២៖ តួនាទី និងភារកិច្ចរបស់ការិយាល័យនីមួយៗ

### ១. ការិយាល័យចុះបញ្ជីម៉ាកពាណិជ្ជកម្ម

ការិយាល័យចុះបញ្ជីម៉ាកពាណិជ្ជកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។ ការិយាល័យចុះបញ្ជីម៉ាកពាណិជ្ជកម្មមានតួនាទី និងភារកិច្ចមួយចំនួនដូចជា៖

- រៀបចំនីតិវិធី និង លិខិតបទដ្ឋានគតិយុត្ត ទាក់ទងនឹងការងារចុះបញ្ជីម៉ាកពាណិជ្ជកម្ម
- រៀបសំណើ និងអនុវត្តគម្រោងទាក់ទងនឹងការងារចុះបញ្ជីម៉ាកពាណិជ្ជកម្ម
- ស្រាវជ្រាវម៉ាកមុនការស្នើសុំចុះបញ្ជីម៉ាក
- ត្រួតពិនិត្យបឋមចំពោះម៉ាកដែលបានដាក់ពាក្យ
- ត្រួតពិនិត្យខ្លឹមសារលម្អិតរបស់ម៉ាក
- ស្រាវជ្រា និងវាយតម្លៃម៉ាក និងម៉ាកល្បី
- ទទួល និងដោះស្រាយបណ្ដឹងតវ៉ា និងបណ្ដឹងជំទាស់មុនពេលម៉ាកត្រូវបានចុះបញ្ជី
- ចុះបញ្ជីម៉ាក និងផ្តល់វិញ្ញាបនបត្រ
- កត់ត្រាការប្តូរឈ្មោះ ប្តូរអាសយដ្ឋានម្ចាស់ម៉ាក ការរួមបញ្ចូលគ្នានៃម៉ាក និងការផ្ទេរសិទ្ធិគ្រប់គ្រងម៉ាក មុនពេលម៉ាកត្រូវបានចុះបញ្ជី
- រៀបចំនិងអនុវត្តការចុះបញ្ជីម៉ាកតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (Automation)

ជាពិសេស ការិយាល័យចុះបញ្ជីម៉ាកពាណិជ្ជកម្មអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹងនាំប្រគល់ជូន[៥៧]។

[៥៥] ប្រកាសស្តីពីការកែសម្រួលនិងបង្កើតការិយាល័យបន្ថែមចំណុះឱ្យនាយកដ្ឋានកម្មសិទ្ធិបញ្ញា,ប្រក.បល.ណ.លេខ១៧២ ព, ១៦ ឧសភា ២០១៦ ,ប្រការ២។

[៥៦] ប្រកាសស្តីពីការកែសម្រួលនិងបង្កើតការិយាល័យបន្ថែមចំណុះឱ្យនាយកដ្ឋានកម្មសិទ្ធិបញ្ញា,ប្រក.បល.ណ.លេខ១៧២ ព , ១៦ ឧសភា ២០១៦ ,ប្រការ២៣។

[៥៧] ប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ,ប្រក.បល.ណ.លេខ២០៦ ព ,២៤ កក្កដា ២០១៤ ,ប្រការ៤។

## ២. ការិយាល័យចុះបញ្ជីម៉ាកអន្តរជាតិ

ការិយាល័យចុះបញ្ជីម៉ាកអន្តរជាតិ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។ ការិយាល័យចុះបញ្ជីម៉ាកអន្តរជាតិមានតួនាទី និងភារកិច្ចដូចជា៖

- រៀបចំនីតិវិធី និងលិខិតបទដ្ឋានគតិយុត្តិ ទាក់ទងនឹងការងារចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិ
- រៀបចំសំណើ និងអនុវត្តគម្រោង ទាក់ទងនឹងការងារចុះបញ្ជីម៉ាកជាលក្ខណៈ អន្តរជាតិ
- គ្រប់គ្រង តាមដានការទូទាត់កម្រៃចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិ ដោយសហការជាមួយការិយាល័យរដ្ឋបាលទូទៅ និងការិយាល័យស្វ័យប្រវត្តិកម្ម និងនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុនៃក្រសួងពាណិជ្ជកម្ម
- ផ្តល់វិញ្ញាបនបត្រចុះបញ្ជីម៉ាកជាអន្តរជាតិតាមការស្នើសុំ
- ក្រើនរំលឹកការមកដាក់ពាក្យធ្វើប្រតិវេទន៍ប្រើប្រាស់ ឬមិនប្រើប្រាស់
- បំពេញភារកិច្ចក្នុងការចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិ និងកិច្ចការពារ ដោយអនុលោមតាមវិធីសារទីក្រុងម៉ាកឌ្រីដ (Madrid Protocol) និងបទប្បញ្ញត្តិនានាក្នុងនាមជា៖
  - ប្រទេសដើម (Office of Origin)
  - ប្រទេសហត្ថលេខីដែលបានជ្រើសរើស (Office of the Designated Contracting Party)

ជាពិសេស ការិយាល័យចុះបញ្ជីម៉ាកអន្តរជាតិបានអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹងនាំប្រគល់ជូន[៥៨]។

## ៣. ការិយាល័យក្រោយចុះបញ្ជីម៉ាកពាណិជ្ជកម្ម

ការិយាល័យក្រោយចុះបញ្ជីម៉ាកពាណិជ្ជកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។ ការិយាល័យក្រោយចុះបញ្ជីម៉ាកពាណិជ្ជកម្មមានតួនាទី និងភារកិច្ចដូចជា៖

- រៀបចំនីតិវិធី និងលិខិតបទដ្ឋានគតិយុត្តិ ទាក់ទងនឹងការងារក្រោយចុះបញ្ជី
- រៀបចំសំណើ និងអនុវត្តគម្រោងទាក់ទងនឹងការងារក្រោយចុះបញ្ជី
- កត់ត្រាប្រតិវេទន៍ប្រើប្រាស់ ឬមិនប្រើប្រាស់ម៉ាក
- ក្រើនរំលឹកមកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសាជាថ្មី
- ត្រួតពិនិត្យពាក្យស្នើសុំ ចុះបញ្ជីម៉ាកសាជាថ្មី និងពាក្យស្នើសុំផ្លាស់ប្តូរនានា ក្រោយម៉ាកត្រូវបានចុះបញ្ជីរួច

[៥៨] ប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ,ប្រក.បល.ណ.លេខ២០៦ ព ,២៤ កក្កដា ២០១៤ ,ប្រការ៥។

- ចុះបញ្ជីម៉ាករួច
- កត់ត្រា៖
  - ការប្តូរឈ្មោះ និងការប្តូរអាសយដ្ឋាន
  - ការប្តូរម្ចាស់កម្មសិទ្ធិ
  - ការរួមបញ្ចូលគ្នានៃម្ចាស់ម៉ាក
  - ការកែតម្រូវផ្សេងៗ
  - ការផ្តល់អាជ្ញាប័ណ្ណ (Licensing)
  - ការផ្តល់សិទ្ធិធ្វើអាជីវកម្មពិសេស (Franchising)
- ចុះបញ្ជីម៉ាកសាជាថ្មី និងកត់ត្រាផ្សេងតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (Automation)
- ពិនិត្យពាក្យស្នើសុំទទួលស្គាល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ ដែលបានចុះបញ្ជីរួច និងរៀបចំសំណុំឯកសារ ដើម្បីស្នើសុំសេចក្តីសម្រេចពីថ្នាក់ដឹកនាំក្រសួង

ជាពិសេស ការិយាល័យក្រោយចុះបញ្ជីម៉ាកពាណិជ្ជកម្ម អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹងនាំប្រគល់ជូន[៥៩]។

## ៤. ការិយាល័យម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ និងព័ត៌មានសម្ងាត់ពាណិជ្ជកម្ម

ការិយាល័យម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ និងព័ត៌មានសម្ងាត់ពាណិជ្ជកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រនធានមួយចំនួនជាជំនួយការ។ ការិយាល័យម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ និងព័ត៌មានសម្ងាត់ពាណិជ្ជកម្មមានតួនាទី និងភារកិច្ចដូចជា៖

- រៀបចំនីតិវិធី និងលិខិតបទដ្ឋានគិតយុត្តិ ទាក់ទងនឹងការងារចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកបញ្ជាក់អំពីចរិកលក្ខណៈទំនិញ និងសេវា (Certification Mark) កិច្ចការពារព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជ
- រៀបចំសំណើ និងអនុវត្តគម្រោងទាក់ទង នឹងការងារចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកបញ្ជាក់អំពីចរិកលក្ខណៈទំនិញ និងសេវា (Certification Mark) កិច្ចការពារព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជ
- សហការជាមួយអង្គភាព មន្ទីរពាក់ព័ន្ធ ត្រួតពិនិត្យស្រាវជ្រាវ និងកំណត់ទំនិញមានសក្តានុពលជាមួយម៉ាកសម្គាល់ភូមិសាស្ត្រ

[៥៩] ប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ,ប្រក.បល.ណ.លេខ២០៦ ព ,២៤ កក្កដា ២០១៤ ,ប្រការ៦។

- សហការជាមួយអង្គភាព មន្ទីរពាក់ព័ន្ធ រៀបចំពាក្យស្នើសុំម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជា
- ត្រួតពិនិត្យពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រកម្ពុជា និងបរទេស
- ពិនិត្យខ្លឹមសារសៀវភៅបន្ទុក
- ពិនិត្យ និងវាយតម្លៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញស្របតាមសៀវភៅបន្ទុក
- ចុះបញ្ជី និងផ្តល់វិញ្ញាបនបត្រ ឬបដិសេធម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជា និងបរទេស
- សហការជាមួយអង្គភាព មន្ទីរពាក់ព័ន្ធ តាមដានម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្រោយចុះបញ្ជី
- សហការជាមួយអង្គភាព មន្ទីរពាក់ព័ន្ធ គ្រប់គ្រង សម្របសម្រួល និងអនុវត្តនីតិវិធីក្នុងកិច្ចការពារព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជកម្ម
- ពិនិត្យ និងចុះបញ្ជីម៉ាកសមូហភាព និងម៉ាកបញ្ជាក់អំពីចរិតលក្ខណៈទំនិញ និងសេវា (Certification Mark) ឬបដិសេធ
- សហការជាមួយអង្គភាព មន្ទីរពាក់ព័ន្ធ គ្រប់គ្រង និងសម្របសម្រួលព្រមទាំងការពារចំណេះដឹងប្រពៃណី ការសម្តែងមានលក្ខណៈវប្បធម៌ប្រពៃណី និងប្រភពធនធានសេណេទិច (Genetic Resource)

ជាពិសេស ការិយាល័យម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ និងព័ត៌មានសម្ងាត់ពាណិជ្ជកម្ម ធ្វើការអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន[៦០]។

## ៥. ការិយាល័យវិវាទ

ការិយាល័យវិវាទ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។ ការិយាល័យវិវាទមានតួនាទី និងភារកិច្ចដូចជា៖

- រៀបចំនីតិវិធី និងលិខិតបទដ្ឋានគតិយុត្តិ ទាក់ទងនឹងការងារដោះស្រាយវិវាទ
- រៀបចំសំណើ និងអនុវត្តគម្រោងទាក់ទងនឹងការងារដោះស្រាយវិវាទ
- ពិនិត្យ និងដោះស្រាយបណ្តឹងជំទាស់នឹងការចុះបញ្ជី ការធ្វើមោឃភាព និងការលុបចោលម៉ាក ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកបញ្ជាក់អំពី ចរិកលក្ខណៈទំនិញ និងសេវា (Certification Mark) និងការទទួលស្គាល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ
- ពិនិត្យ និងវាយតម្លៃអំពីការរំលោភបំពានម៉ាក ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកបញ្ជាក់អំពី ចរិកលក្ខណៈទំនិញ និងសេវា (Certification Mark) តាមការស្នើសុំរបស់ភាគីពាក់ព័ន្ធ អាជ្ញាធរ និងតុលាការមានសមត្ថកិច្ច

[៦០] ប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ,ប្រក.បល.ណ.លេខ២០៦ ព ,២៥ កក្កដា ២០១៤ ,ប្រការ៧។

- ពិនិត្យ និងដោះស្រាយវិវាទ នៃការរំលោភបំពានម៉ាក ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកបញ្ជាក់អំពី ចរិកលក្ខណៈទំនិញ និងសេវា (Certification Mark) និងការទទួលស្គាល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ ការផ្តល់អាជ្ញាប័ណ្ណ និងសិទ្ធិអាជីវកម្មពិសេស ព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជកម្ម តាមនីតិវិធីសម្រុះសម្រួលវិវាទ
- សហការជាមួយអង្គភាព មន្ទីរពាក់ព័ន្ធពិនិត្យធ្វើការសង្កេត និងបញ្ឈប់ការក្លែងបន្លំម៉ាក ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកបញ្ជាក់អំពី ចរិកលក្ខណៈទំនិញ និងសេវា (Certification Mark) និងការទទួលស្គាល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ ការផ្តល់អាជ្ញាប័ណ្ណ និងសិទ្ធិអាជីវកម្មពិសេស ព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជកម្ម ដែលមានទំនាស់នៅលើទីផ្សារ
- សហការជាមួយអង្គភាព មន្ទីរពាក់ព័ន្ធ ពិនិត្យ និងដោះស្រាយវិវាទផ្សេងៗទៀត ដូចជា ចំណេះដឹងប្រពៃណី ការបង្ហាញដែលមានលក្ខណៈវប្បធម៌ប្រពៃណី និងប្រភពធនធានសេណេទិច (Genetic Resource)
- រៀបចំឱ្យមានសេវនាការក្នុងការដោះស្រាយវិវាទតាមការចាំបាច់ ឬមានសំណូមពរភាគីពាក់ព័ន្ធ
- ចូលរួមបំភ្លឺនៅតុលាការលើករណីវិវាទកម្មសិទ្ធិបញ្ញា តាមការស្នើសុំ
- រៀបចំឯកសារ និងកម្មវិធីផ្សព្វផ្សាយ ស្តីពីការរំលោភបំពានកម្មសិទ្ធិបញ្ញាដើម្បីបង្កើតការយល់ដឹងជាសាធារណៈ និងកាត់បន្ថយការរំលោភបំពាន
- កត់ត្រា និងចងក្រងទិន្នន័យវិវាទកម្មសិទ្ធិបញ្ញាទុកសិក្សាស្រាវជ្រាវ វាយតម្លៃ និងដាក់ចេញនូវគោលការណ៍ថ្មីដើម្បីផ្សព្វផ្សាយជាសាធារណៈ និងនិងកាត់បន្ថយការរំលោភបំពានកម្មសិទ្ធិបញ្ញា

ជាពិសេស ការិយាល័យវិវាទអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន[៦១]។

## ៦. ការិយាល័យសហប្រតិបត្តិការ និងកិច្ចការច្បាប់

ការិយាល័យសហប្រតិបត្តិការ និងកិច្ចការច្បាប់ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។ ការិយាល័យសហប្រតិបត្តិការ និងកិច្ចការច្បាប់មានតួនាទី និងភារកិច្ចដូចជា៖

- ជាសេនាធិការនៃលេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់កម្មសិទ្ធិបញ្ញា
- ទំនាក់ទំនង និងសម្របសម្រួលការងារជាមួយក្រសួង និងស្ថាប័ននានា លើវិស័យកម្មសិទ្ធិបញ្ញា
- រៀបចំសំណើ និងអនុវត្តគម្រោង ទាក់ទងនឹងការងារសហប្រតិបត្តិការ និងកិច្ចការច្បាប់
- សម្របសម្រួលកិច្ចការអន្តរជាតិទាក់ទងនឹងកម្មសិទ្ធិបញ្ញា

[៦១] ប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ,ប្រក.បល.ណ.លេខ២០៦ ព ,២៤ កក្កដា ២០១៤ ,ប្រការ៨។

- សិក្សាស្រាវជ្រាវអំពីអត្ថប្រយោជន៍របស់កម្ពុជា ក្នុងការចូលរួមសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង អនុស្សារណៈ និងច្បាប់នានា ដែលទាក់ទងនឹងវិស័យកម្មសិទ្ធិបញ្ញា
- សហការរៀបចំសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិ និងបែបបទនានា ដែលពាក់ព័ន្ធវិស័យកម្មសិទ្ធិបញ្ញា
- ចូលរួមពិនិត្យ និងកែសម្រួលសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ
- ស្រាវជ្រាវ និងតាមដានអំពីនិន្នាការអភិវឌ្ឍន៍កម្មសិទ្ធិបញ្ញានៅលើសកលលោក
- សហការជាមួយដៃគូអភិវឌ្ឍន៍ក្នុងការពង្រឹង និងអភិវឌ្ឍន៍វិស័យកម្មសិទ្ធិបញ្ញា
- ចូលរួមកិច្ចប្រជុំ និងចរចារជាមួយប្រទេសជាដៃគូ ទាក់ទងនឹងវិស័យកម្មសិទ្ធិបញ្ញា
- ផ្តល់ប្រឹក្សាផ្នែកច្បាប់កម្មសិទ្ធិបញ្ញា
- ធ្វើរបាយការណ៍ស្តីពី កិច្ចប្រជុំគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា
- សហការជាមួយនឹងការិយាល័យក្នុងនាយកដ្ឋាន និងស្ថាប័ននានា ក្នុងការដោះស្រាយបញ្ហាផ្សេងៗ ពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញាជាមួយបរទេស
- រៀបចំសំណើ និងគ្រប់គ្រងគម្រោងនានារបស់នាយកដ្ឋាន

ជាពិសេស ការិយាល័យសហប្រតិបត្តិការ និងកិច្ចការច្បាប់អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន[៦២]។

## ៧. ការិយាល័យអប់រំ និងចំណេះដឹងសាធារណៈ

ការិយាល័យអប់រំ និងចំណេះដឹងសាធារណៈ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។ ការិយាល័យអប់រំ និងចំណេះដឹងសាធារណៈមានតួនាទី និងភារកិច្ចដូចជា៖

- រៀបចំនីតិវិធី និងលិខិតបទដ្ឋាន ទាក់ទងនឹងការងារអប់រំ និងចំណេះដឹងសាធារណៈ
- រៀបចំសំណើ និងអនុវត្តគម្រោង ទាក់ទងនឹងការងារអប់រំ និងចំណេះដឹងសាធារណៈ
- លើកកម្ពស់ការយល់ដឹងពីកម្មសិទ្ធិបញ្ញា ដល់សាធារណៈជន តាមរយៈការចែកជូនខិតប័ណ្ណ សៀវភៅអប់រំខ្លីៗ និងអត្ថបទច្បាប់ ព្រមទាំងធ្វើការផ្សព្វផ្សាយតាមការសែត ទស្សនាវដ្តី និងទូរទស្សន៍ជាដើម
- បង្កើត និងអនុវត្តកម្មវិធីបណ្តុះបណ្តាលចំណេះដឹង ពីកម្មសិទ្ធិបញ្ញា ដល់គ្រូបង្គោល មន្ត្រី សិស្ស និស្សិត និងសាធារណៈជន តាមរាជធានីភ្នំពេញ

[៦២] ប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ,ប្រក.បល.ណ.លេខ២០៦ ព ,២៤ កក្កដា ២០១៤ ,ប្រការ៩។

- រៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលបេសកម្ម ទស្សនកិច្ចសិក្សា និងទិវាកម្មសិទ្ធិបញ្ញាជាតិ និងពិភពលោក
- រៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក
- សហការជាមួយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ នៃក្រសួងពាណិជ្ជកម្ម ដើម្បីទទួលបណ្តុះបណ្តាលចំណេះដឹងផ្នែកកម្មសិទ្ធិបញ្ញា
- សម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ក្នុងការបញ្ចូលកម្មវិធីសិក្សាកម្មសិទ្ធិបញ្ញា នៅតាមគ្រឹះស្ថានអប់រំនិងវិជ្ជាជីវៈ
- ប្រមូលចងក្រងឯកសារដែលបានបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេស
- រៀបចំ គ្រប់គ្រង និងអភិវឌ្ឍន៍បណ្ឌិតសភាកម្មសិទ្ធិ (IP Academy) មជ្ឈមណ្ឌលគាំទ្របច្ចេកវិទ្យា និងការច្នៃប្រឌិតថ្មី (Technology and Innovation Srpport Center TISC) បញ្ជរ ឬមជ្ឈមណ្ឌលពិគ្រោះយោបល់សម្រាប់សហគ្រាសធុនតូច និងមធ្យម (SMEs Consulting Desk/Center) មជ្ឈមណ្ឌលព័ត៌មានកម្មសិទ្ធិបញ្ញា (IP Information Center) បណ្ណាល័យតម្កល់ឯកសារអង្គការកម្មសិទ្ធិពិភពលោក (WIPO Depositary Library) និងវគ្គបណ្តុះបណ្តាលតាមបណ្តាញអ៊ីនធឺណែត (Online Training) ក្រោមគម្រោងរបស់កម្មសិទ្ធិបញ្ញាពិភពលោក និងដៃគូអភិវឌ្ឍន៍

ជាពិសេស ការិយាល័យអប់រំ និងចំណេះដឹងសាធារណៈអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន[៦៣]។

## ៨. ការិយាល័យរដ្ឋបាលទូទៅ

ការិយាល័យរដ្ឋបាលទូទៅ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានចំនួនច្រើនបំផុតពីររូបទៅបួនរូបជាជំនួយការ[៦៤]។ ការិយាល័យរដ្ឋបាលទូទៅមានតួនាទី និងភារកិច្ចដូចជា៖

- រៀបចំគំរូលិខិតបទដ្ឋានគតិយុត្ត ទាក់ទងនឹងការងាររដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំស្នើ និងអនុវត្តគម្រោងលើវិស័យកម្មសិទ្ធិបញ្ញា ទាក់ទងនឹងការងារគ្រប់គ្រងរដ្ឋបាលរបស់នាយកដ្ឋាន
- ទទួលបន្ទុកការងាររដ្ឋានទូទៅ និងបុគ្គលិកក្នុងនាយកដ្ឋាន ព្រមទាំងសម្របសម្រួលការងារនានាជាមួយនាយកដ្ឋានពាក់ព័ន្ធក្នុងក្រសួង

[៦៣] ប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ,ប្រក.បល.ណ.លេខ២០៦ ព ,២៩ កក្កដា ២០១៩ ,ប្រការ១០។

[៦៤] ប្រកាសស្តីពីការកែសម្រួលនិងបង្កើតការិយាល័យបន្ថែមចំណុះឱ្យនាយកដ្ឋានកម្មសិទ្ធិបញ្ញាលេខ ,១៧២ ព ,ប្រក.បល.ណ.១៦ ឧសភា ២០១៦ ,ប្រការ៣។

- ធ្វើរបាយការណ៍ការងាររបស់នាយកដ្ឋាន
- រៀបចំសម្របសម្រួលការបោះពុម្ពផ្សាយព្រឹត្តិប័ត្តផ្លូវការ
- គ្រប់គ្រងបញ្ជរទទួលពាក្យស្នើសុំ
- គ្រប់គ្រង និងថែរក្សាសម្ភារៈ ឧបករណ៍ និងឯកសាររបស់នាយកដ្ឋាន
- គ្រប់គ្រងថវិកាចំណូល និងចំណាយរបស់នាយកដ្ឋាន
- សហការជាមួយមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ក្នុងការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាក ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ ម៉ាកសមូហភាព ម៉ាកបញ្ជាក់អំពីចរិកលក្ខណៈទំនិញ និងសេវា (Certification Mark) ក្នុងព្រះរាជាណាចក្រកម្ពុជា
- ទទួលពាក្យស្នើសុំចុះបញ្ជីម៉ាក ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ ម៉ាកសមូហភាព ម៉ាកបញ្ជាក់អំពី ចរិកលក្ខណៈទំនិញ និងសេវា (Certification Mark)
- សហការជាមួយមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ក្នុងការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកសារឡើងវិញ និងពាក្យស្នើសុំផ្សេងៗ ក្រោយពីម៉ាកត្រូវបានចុះបញ្ជី ក្នុងព្រះរាជាណាចក្រកម្ពុជា
- ទទួលពាក្យស្នើសុំចុះបញ្ជីម៉ាក ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ ម៉ាកសមូហភាព ម៉ាកបញ្ជាក់អំពីចរិកលក្ខណៈទំនិញ និងសេវា (Certification Mark) ពីបរទេស
- ផ្តល់លេខដាក់ពាក្យ និងកាលបរិច្ឆេទទទួលពាក្យ តាមប្រព័ន្ធអេឡិចត្រូនិច
- ចេញលិខិតទទួលស្គាល់ការដាក់ពាក្យ ឬណែនាំ ឬបដិសេធពាក្យស្នើសុំចុះបញ្ជី
- គ្រប់គ្រង និងប្រគល់វិញ្ញាបនបត្រចុះបញ្ជី និងឯកសារផ្សេងៗ

ជាពិសេស ការិយាល័យទូទៅអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន[៦៥]។

## ៩. ការិយាល័យស្វ័យប្រវត្តិកម្ម និងព័ត៌មានវិទ្យា

ការិយាល័យស្វ័យប្រវត្តិកម្មនិងព័ត៌មានវិទ្យា ដឹកនាំដោយប្រធានមួយរូបនិងអនុប្រធានចំនួនច្រើនបំផុតពីររូបទៅបួនរូបជាជំនួយការ[៦៦]។ ការិយាល័យស្វ័យប្រវត្តិកម្ម និងព័ត៌មានវិទ្យា មានតួនាទីនិងភារកិច្ចដូចជា៖

- រៀបចំនីតិវិធី និងលិខិតបទដ្ឋាន ទាក់ទងនឹងការងារព័ត៌មានវិទ្យា និងការងារទំនាក់ទំនងសាធារណៈសម្រាប់នាយកដ្ឋាន

---

[៦៥] ប្រកាសស្តីពីការកែសម្រួលនិងបង្កើតការិយាល័យបន្ថែមចំណុះឱ្យនាយកដ្ឋានកម្មសិទ្ធិបញ្ញាលេខ ,១៧២ ព ,ប្រក.បល.ណ.១៦ ឧសភា ២០១៦ ,ប្រការ២។

[៦៦] ប្រកាសស្តីពីការកែសម្រួលនិងបង្កើតការិយាល័យបន្ថែមចំណុះឱ្យនាយកដ្ឋានកម្មសិទ្ធិបញ្ញាលេខ ,១៧២ ព ,ប្រក.បល.ណ.១៦ ឧសភា ២០១៦ ,ប្រការ៣។

- រៀបចំសំណើ និងអនុវត្តគម្រោងទាក់ទងនឹងការងារព័ត៌មានវិទ្យា និងការងារទំនាក់ទំនងសាធារណៈសម្រាប់នាយកដ្ឋាន
- រៀបចំ គ្រប់គ្រង និងថែរក្សាប្រព័ន្ធព័ត៌មានវិទ្យារបស់នាយកដ្ឋាន ប្រព័ន្ធប្រតិបត្តិកម្មកម្មសិទ្ធិបញ្ញា (IPAS) ប្រព័ន្ធឯកសារឌីជីថលភាវូបនីយកម្ម (EDMS) និងប្រព័ន្ធទិន្នន័យផ្សេងៗទៀត
- រៀបចំ គ្រប់គ្រង និងថែរទាំប្រព័ន្ធអ៊ីនធឺណែត និងណែតវើក Internet Network របស់នាយកដ្ឋាន
- រៀបចំ គ្រប់គ្រង និងជួសជុល កុំព្យូទ័រ Software and Hardware
- រៀបចំ គ្រប់គ្រងការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធអ៊ីនធឺណែត Online Filing ព្រមទាំងផ្តល់លេខដាក់ពាក្យ និងកាលបរិច្ឆេទការដាក់ពាក្យតាមប្រព័ន្ធ អ៊ីនធឺណែត Online Filing
- បញ្ជូនរាល់ឯកសារឆ្លើយឆ្លងផ្សេងៗ ទាក់ទងនឹងការស្នើសុំចុះបញ្ជីម៉ាកទៅក្នុងប្រព័ន្ធឯកសារឌីជីថលភាវូបនីយកម្ម (Digitalization Documents (EDMS)
- បញ្ជូនរាល់ឯកសារឆ្លើយឆ្លងផ្សេងៗ និងធ្វើការជូនដំណឹងដល់ម្ចាស់ម៉ាក និងភ្នាក់ងារតំណាងតាមប្រព័ន្ធអ៊ីនធឺណែដោយស្វ័យប្រវត្តិ
- ផ្តល់ព័ត៌មាន និងពិគ្រោះយោបល់ ពាក់ព័ន្ធការស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធអ៊ីនធឺណែត Online និងព័ត៌មានផ្សេងៗដល់សាធារណៈជន
- សហការជាមួយដៃគូអភិវឌ្ឍផ្សេងៗ ដើម្បីពង្រឹង និងអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា
- សហការជាមួយការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ពាក់ព័ន្ធទៅនឹងការទូទាត់កម្រៃតាមប្រព័ន្ធអ៊ីនធឺណែត Online Payment និងការងារផ្សេងៗទៀត
- ផ្សព្វផ្សាយ តួនាទី ភារកិច្ច ការទទួលខុសត្រូវ សកម្មភាពការងារផ្សេងៗ របស់នាយកដ្ឋានដល់សាធារណៈជន និងវិស័យឯកជនតាមប្រព័ន្ធអ៊ីនធឺណែត វេបសាយ និងតាមបណ្តាញផ្សេងៗ
- គ្រប់គ្រងកែសម្រួល រៀបចំ និងធ្វើបច្ចុប្បន្នភាពវេបសាយរបស់នាយកដ្ឋាន
- បោះពុម្ពផ្សាយព្រឹត្តិបត្រផ្លូវការ ច្បាប់ អនុក្រឹត្យ ប្រកាស សេចក្តីជូនដំណឹង និងព័ត៌មានផ្សេងៗ ទាក់ទងនឹងវិស័យកម្មសិទ្ធិបញ្ញាតាមប្រព័ន្ធអ៊ីនធឺណែត និងតាម រយៈវេបសាយរបស់នាយកដ្ឋាន

ជាពិសេស ការិយាល័យស្វ័យប្រវត្តិកម្ម និងព័ត៌មានវិទ្យាអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន[៦៧]។

[៦៧] ប្រកាសស្តីពីការកែសម្រួលនិងបង្កើតការិយាល័យបន្ថែមចំណុះឱ្យនាយកដ្ឋានកម្មសិទ្ធិបញ្ញាលេខ,១៧២ ព ,ប្រក.បល.ណ.១៦ ឧសភា ២០១៦ ,ប្រការ២។

# ផ្នែកទី ២
# គុណសម្បត្តិ និងគុណវិបត្តិ

យោងតាមរយៈរចនាសម្ព័ន្ធរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលមានតួនាទី និងភារកិច្ចក្នុងការគ្រប់គ្រងលើកម្មសិទ្ធិបញ្ញា។ យន្តការការរៀបចំអនុវត្តន៍លើការងារកម្មសិទ្ធិបញ្ញាមិនទាន់មានភាពល្អទាំងស្រុងនៅឡើយទេ ពីព្រោះវាអាចផ្តល់នូវគុណសម្បត្តិ និងគុណវិបត្តិមួយចំនួនផងដែរ។

## កថាភាគទី១៖ គុណសម្បត្តិ

នាយកដ្ឋានកម្មសិទ្ធិបញ្ញាស្ថិតនៅក្រោមឱវាទរបស់ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា បានប្រមូលផ្តុំនូវធនធានមន្ត្រីបុគ្គលិកជំនាញ និងលើកកម្ពស់ទាក់ទងទៅនឹងវិស័យកម្មសិទ្ធិបញ្ញា ទៅតាមជំនាញនីមួយៗឱ្យបានល្អប្រសើរជាងមុន។ តាមរយៈនៅការប្រមូលផ្តុំមន្ត្រីបុគ្គលិកជំនាញគ្រប់គ្រងផ្នែក ក្នុងនាយកដ្ឋានកម្មសិទ្ធិបញ្ញាអាចជួយឱ្យពួកគេ បានធ្វើការផ្លាស់ប្តូរ ឬផ្ទេរនូវចំណេះដឹង និងបទពិសោធន៍ពីគ្នាទៅវិញទៅមក កត្តាទាំងអស់នេះបានជំរុញឱ្យកិច្ចដំណើរការនៅក្នុងនាយកដ្ឋានកម្មសិទ្ធិបញ្ញា មានភាពជឿនលឿនទៅមុខ ជាលំដាប់ និងដំណើរការកាន់តែល្អប្រសើរជាបន្តបន្ទាប់។ ជាពិសេស ក្នុងករណីមន្ត្រីបុគ្គលិកមានការសហការគ្នាបានល្អ និងយកចិត្តទុកដាក់ទៅលើការងាររបស់ខ្លួន ដូចជាការងារចុះបញ្ជី ហើយការចុះបញ្ជីនិងកាន់តែមានការកើនឡើងជាលំដាប់ កត្តានេះហើយដែលធ្វើឱ្យរដ្ឋទទួលបានប្រាក់ចំណូល ពីការចុះបញ្ជីកាន់តែកើនឡើង។ បើរដ្ឋមានប្រាក់ចំណូលខ្ពស់នោះមន្ត្រីបុគ្គលិក ក៏អាចទទួលបានប្រាក់បៀវត្សសមរម្យល្អជាងមុន និងអាចលុបបំបាត់នូវអំពើពុករលួយផងដែរ។

## កថាភាគទី២៖ គុណវិបត្តិ

ឆ្លងតាមការសិក្សាស្រាវជ្រាវនិងការអនុវត្ត និងសកម្មភាពការងារដែលមានគុណសម្បត្តិមួយចំនួនខាងលើនោះ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ដែលជាចំណុះឱ្យក្រសួងពាណិជ្ជកម្ម ក៏មានបញ្ហាចោទប្រកាន់ខ្លះផងដែរ។ នាយកដ្ឋានកម្មសិទ្ធិបានសហការជាច្រើនជាមួយអង្គភាព ស្ថាប័នពាក់ព័ន្ធទៅផ្នែកកម្មសិទ្ធិបញ្ញា ដូចជានាយកដ្ឋានឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងនាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

ដោយសារយន្តការការងារអនុវត្តរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា គ្រប់គ្រងលើផ្នែកកម្មសិទ្ធិបញ្ញា ក៏មានគុណវិបត្តិមួយចំនួនកើតឡើងផងដែរ ដូចនេះនាយកដ្ឋានកម្មសិទ្ធិបញ្ញាអនុវត្តន៍ការងារ មានចំណុចខ្វះខាតដោយការយល់ដឹងមន្ត្រីអនុវត្តន៍ច្បាប់កម្មសិទ្ធិបញ្ញានូវមានកំរិត ពិសេសនៅតាមអង្គភាពស្ថាប័នពាក់ព័ន្ធលើកម្ម

សិទ្ធិបញ្ញា នៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះ អង្គភាពពាក់ព័ន្ធផ្នែកកម្មសិទ្ធិបញ្ញា គួរតែសហការបង្រួមស្ថាប័ន ជាមួយនាយកដ្ឋានកម្មសិទ្ធិបញ្ញា ឱ្យបានល្អប្រសើរជាងមុនថែមទៀតនាពេលអនាគត។

# ជំពូកទី៣

# ការរំលោភលើម៉ាក និងការដោះស្រាយវិវាទ

ការប្រើប្រាស់ម៉ាកគ្រប់រូបភាពដោយពុំមានការអនុញ្ញាតពីម្ចាស់សិទ្ធិ ត្រូវបានចាត់ទុកថាជាអំពើរំលោភម៉ាក។ គោលការណ៍នេះ ត្រូវអនុវត្តន៍តែចំពោះការប្រើប្រាស់ម៉ាក នៅក្នុងវិស័យពាណិជ្ជកម្មប៉ុណ្ណោះ មានន័យថាការប្រើប្រាស់ជាលក្ខណៈឯកជនមិនត្រូវស្ថិតនៅក្នុងការអនុវត្តនៃច្បាប់ការពារម៉ាកនោះទេ។ នៅក្នុងក្របខណ្ឌនៃការអនុវត្តម៉ាក អំពើរំលោភម៉ាកអាចកើតមានឡើងតាមបីរូបភាព គឺការក្លែងបន្លំម៉ាក ការធ្វើត្រាប់តាមម៉ាក និងការប្រើប្រាស់ម៉ាកគេដោយពុំមានការអនុញ្ញាត។ ផលិតផលដែលកើតចេញពីអំពើខាងនេះ ត្រូវបានចាត់ទុកថាជាទំនិញដែលពាក់ម៉ាកក្លែងក្លាយ។ ច្បាប់ម៉ាក នៃប្រទេសកម្ពុជាបញ្ញត្តិអំពីវិធានការសមស្របមួយចំនួន ដែលម្ចាស់ម៉ាកអាចធ្វើបាន ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួន។

## ផ្នែកទី១

## ការរំលោភលើម៉ាក

ដោយព្រះរាជាណាចក្រកម្ពុជាយើង បានចូលជាសមាជិកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ក៏ដូច ជាអនុសញ្ញាទីក្រុងប៉ារីស កិច្ចព្រមព្រៀង Trips ជាដើម។ នៅក្នុងអនុសញ្ញាទីក្រុងប៉ារីស មាត្រា ១០ ស្ទួន ចំណុច ៣ បានកំណត់កាតព្វកិច្ចចំពោះរដ្ឋជាសមាជិកទាំងឡាយ ឲ្យធ្វើការហាមឃាត់រាល់ សកម្មភាពទាំងអស់ដែលមានដូចជា សកម្មភាពដែលបង្កើតឲ្យមានការភ័ន្តច្រឡំ ទោះបីជាបានបង្កើតដោយរបៀបណាក៏ដោយ ដែលកើតឡើងពីសកម្មភាពពាណិជ្ជកម្ម ឧស្សាហកម្មនៃអ្នកប្រកួតប្រជែង។ ដើម្បីខិតខំធ្វើទៅតាមសេចក្តីបញ្ញត្តិរបស់កិច្ចព្រមព្រៀងទាំងឡាយដែលបានចែង ព្រះរាជាណាចក្រកម្ពុជាក៏បានប្រឹងប្រែងយ៉ាងពេញទំហឹងក្នុងការអនុវត្តន៍វិស័យកម្មសិទ្ធិបញ្ញាឲ្យមានភាពរលូន ព្រះរាជាណាចក្រកម្ពុជាក៏បានបង្កើតឲ្យមានច្បាប់មួយចំនួន ដើម្បីធ្វើការគ្រប់គ្រងទៅលើវិស័យនេះ ដែលច្បាប់ទាំងនោះរួមមាន៖ ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះ ត្រង់ជាដើម ហើយជាក់ស្តែងនៅក្នុងច្បាប់នេះក៏បានចែងអំពីការរំលោភបំពាន និងវិធានការនៃការ ដោះស្រាយវិវាទ ក្នុងករណីដែលមានការរំលោភម៉ាកកើតឡើងផងដែរ។ ដូច្នេះនៅពេលដែល មានការរំលោភម៉ាកកើតមានឡើងនៅក្នុងប្រទេសកម្ពុជា កម្ពុជាយើងដោះស្រាយវិវាទនោះ និងអនុវត្តន៍ទៅតាមវិធានការផ្សេងៗ ដែលមានចែងក្នុងច្បាប់កម្ពុជា ដើម្បីបង្ការ និងបង្ក្រាបនូវអំពើរំលោភម៉ាកនៅព្រះរាជាណាចក្រកម្ពុជា។

### កថាភាគទី១៖ ការប្រើប្រាស់ម៉ាកដោយគ្មានការយល់ព្រមពីម្ចាស់ម៉ាក

ការប្រើប្រាស់ម៉ាក ដែលបានចុះបញ្ជីរួចត្រូវមានការយល់ព្រមពីម្ចាស់ម៉ាកជាមុនសិន[៦៨]។ ការប្រើប្រាស់

[៦៨] មាត្រា១១ នៃច្បាប់ម៉ាក

ម៉ាកគ្រប់រូបភាពដោយពុំមានការអនុញ្ញាតពីម្ចាស់ម៉ាក ត្រូវបានគេចាត់ទុកថា ជាអំពើរំលោភម៉ាក។ ការរំលោភសិទ្ធិនៃម្ចាស់ម៉ាកអាចត្រូវបានគេធ្វើឡើងច្រើនរូបភាព និងច្រើន សណ្ឋាន សុទ្ធសឹងត្រូវបានហាមឃាត់ដូចជាតាមរយៈការនាំចូល ការលក់ ការប្រកាសលក់ ឬមានបំណងលក់[៦៩] ហើយច្បាប់ម៉ាកនៃប្រទេសកម្ពុជាក៏បានបញ្ញត្តិអំពីវិធានការសមស្របមួយចំនួន ដែលមានទោសទណ្ឌព្រហ្មណ្ឌ និង រដ្ឋប្បវេណីចំពោះអំពីការផ្សព្វផ្សាយពាណិជ្ជកម្មទំនិញ ដោយបញ្ញត្តិអំពើនៃប្រកាស លក់ត្រូវផ្តន្ទាទោសតាមមាត្រា ៦៦ នៃច្បាប់ម៉ាក។ ក្នុងន័យនេះការប្រកាសលក់អាចត្រូវបានធ្វើឡើង តាមរយៈមធ្យោបាយនៃការផ្សព្វផ្សាយគ្រប់ប្រភេទ។ ប៉ុន្តែចំពោះការប្រើប្រាស់ម៉ាកដោយពុំមានការ អនុញ្ញាតពីម្ចាស់ម៉ាកក្នុងគោលដៅបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ពុំត្រូវចាត់ទុកថាជាអំពើរំលោភម៉ាកឡើយ។ ដូច្នេះការប្រើប្រាស់ផលិតផលជាលក្ខណៈឯកជន ការនាំចូលទំនិញដែលមិនមាន លក្ខណៈពាណិជ្ជកម្ម ដែលដាក់នៅក្នុងអីវ៉ាន់ផ្ទាល់ខ្លួននៃអ្នកដំណើរ មិនត្រូវបានចាត់ទុកថាជាអំពើរំលោភម៉ាកទេ[៧០]។

## កថាភាគទី២៖ ការក្លែងបន្លំម៉ាក

អំពើក្លែងបន្លំម៉ាក គឺជាប្រភេទមួយនៃអំពើរំលោភសិទ្ធិ លើម៉ាកមួយដែលត្រូវហាមឃាត់ ដោយច្បាប់ម៉ាក។ មាត្រា ៦៤ នៃច្បាប់ម៉ាកពុំបានកំណត់អំពីនិយមន័យ នៃការក្លែងបន្លំម៉ាកឡើយ ពោលគឺ ចែងតែអំពីទោសព្រហ្មទណ្ឌ និងទោសពិន័យលើអំពើក្លែងបន្លំម៉ាកតែប៉ុណ្ណោះ។ ជាទូទៅ ការក្លែងបន្លំម៉ាកអាចត្រូវបានធ្វើឡើងតាមពីររូបភាពដូចជា៖ ការផលិតឡើងវិញ និងការធ្វើត្រាប់ តាមម៉ាកដែលបានចុះបញ្ជីរួចឡើងវិញ។

### ១. ការផលិតឡើងវិញនៃម៉ាក

ការផលិតឡើងវិញនៃម៉ាក គឺសំដៅទៅលើការចម្លងដូចទាំងស្រុងទៅនឹងម៉ាកដែលត្រូវបាន គេចុះបញ្ជីរួច ហើយបានប្រើប្រាស់ ឬមានគោលដៅនៃការប្រើប្រាស់ ឬមានគោលដៅនៃការប្រើ ប្រាស់លើប្រភេទនៃទំនិញ ឬសេវាដូចគ្នា។ ការក្លែងបន្លំម៉ាកតាមរយៈការផលិតឡើងវិញត្រូវមានលក្ខខណ្ឌពីរគឺ៖

- ១. ម៉ាកដែលផលិតឡើងវិញនោះត្រូវបានប្រើប្រាស់លើប្រភេទទំនិញ ឬសេវា ដូចគ្នាទៅនឹងប្រភេទទំនិញ ឬសេវានៃម៉ាក។ លក្ខខណ្ឌនេះងាយស្រួលក្នុងការពិចារណាដោយ ពិនិត្យទៅលើប្រភេទនៃទំនិញ ឬសេវានៃម៉ាកដែលបានចុះបញ្ជីរួចលើវិញ្ញាបនបត្រចុះបញ្ជីម៉ាក។
- ២. ចំពោះម៉ាកល្បី ការផលិតឡើងវិញនូវម៉ាក ដែលបានចុះបញ្ជីរួចហើយប្រើប្រាស់លើប្រភេទទំនិញ ឬសេវាដូចគ្នា ឬប្រហាក់ប្រហែលគ្នា ឬដែលពាក់ព័ន្ធគ្នាក៏ដោយ ក៏អាចចាត់ទុកថាជាអំពើក្លែងបន្លំម៉ាកបានដែរ។ ក្នុងករណីនេះ ទោះបីជាចំណុចណាមួយនៃម៉ាកល្បីក៏អាចត្រូវបានចាត់ទុក

[៦៩] មាត្រា៦៦ នៃច្បាប់ម៉ាក

[៧០] មាត្រា៤៧ នៃច្បាប់ម៉ាក

ថាជាការបន្លំដោយផ្នែកនៃម៉ាកល្បីដែរ។ ជាទូទៅករណីនេះ ច្រើនកើតមានចំពោះម៉ាកជាបង្គុំនៃសញ្ញា ឬរូបភាព។

## ២. ការធ្វើត្រាប់តាមម៉ាក

ការធ្វើត្រាប់តាមម៉ាកដែលបានចុះបញ្ជីរួច ជាអំពើរំលោភម៉ាកដែលត្រូវបានដាក់ទោស ដោយមាត្រា ៦៥ នៃច្បាប់ម៉ាក ប៉ុន្តែបញ្ញត្តិនេះមិនបានកំណត់អំពីនិយមន័យនៃការធ្វើត្រាប់តាម ម៉ាកឡើយ។ ការធ្វើត្រាប់តាមម៉ាកគឺជាការផលិតឡើងវិញនូវម៉ាកដែលមានលក្ខណៈដូច ឬប្រហាក់ ប្រហែលដែលធ្វើឲ្យមានការភ័ន្តច្រឡំដល់សាធារណៈជន។ ច្បាប់ម៉ាកពុំបានបញ្ជាក់ច្បាស់លាស់ អំពីភាពខុសគ្នានៃការផលិតឡើងវិញ និងការធ្វើត្រាប់តាមម៉ាកឡើយ។

នៅក្នុងនីតិកម្មសិទ្ធិបញ្ញាបារាំង តុលាការបានធ្វើការបែងចែកភាពខុសគ្នារវាងសញ្ញាទាំងពីរ តាមរយៈសេចក្តីសម្រេច ដោយសង្កត់ធ្ងន់ទៅលើលក្ខណៈនៃម៉ាក ដែលធ្វើឲ្យមានការភ័ន្តច្រឡំដល់សាធារណៈជនជាចំបង។ ដូច្នេះភាពស្រដៀងគ្នាដែលធ្វើឱ្យមានការភ័ន្ត ច្រឡំដល់សាធារណៈជន ជាកត្តាចំបងដើម្បីវិនិច្ឆ័យអំពីអំពើធ្វើត្រាប់តាមម៉ាក។ លក្ខណៈវិនិច្ឆ័យបែបនេះនឹងត្រូវយកមកពិចារណា លើគ្រប់ថ្នាក់នៃផលិតផល និងសេវាចំពោះការធ្វើត្រាប់តាមម៉ាកល្បី។

## ៣. ការច្រកផលិតផល

ការច្រកផលិតផល គឺសំដៅទៅលើការយកសំបកវេចខ្ចប់ដែលមានម៉ាកដែលបានចុះបញ្ជី រួចទៅច្រកដាក់ផលិតផលថ្មីដែលពុំមែនជាផលិតផលនៃម្ចាស់ម៉ាក។ ចំណុចនេះ ពុំត្រូវបានកំណត់នៅក្នុងច្បាប់ម៉ាករបស់ព្រះរាជាណាចក្រកម្ពុជាទេ ប៉ុន្តែនៅក្នុងការបក ស្រាយនៃមាត្រា ១១ នៃច្បាប់ម៉ាកក្នុងន័យទូលាយ អំពើនេះក៏អាចចាត់ទុកថាជាអំពើរំលោភម៉ាកផងដែរ។

# ផ្នែកទី ២
# យន្តការដំណោះស្រាយ

ច្បាប់ម៉ាកកំណត់អំពើវិធានការសមស្របមួយចំនួន ដើម្បីទប់ស្កាត់ និងបង្ក្រាប បទល្មើសរំលោភម៉ាកតាមរយៈការនាំចូលផលិតផលក្លែងបន្លំ ក្នុងទីផ្សារព្រះរាជាណាចក្រកម្ពុជា។ វិធានទាំងនោះ បានធ្វើការសម្រប សម្រួលក្នុងដំណើរនៃការអនុវត្តច្បាប់ ផ្នែកកម្មសិទ្ធិបញ្ញានៅព្រះរាជាណាចក្រកម្ពុជា ឱ្យមានភាពប្រសើរជាមុន និងមានភាពយុត្តិធម៌សម្រាប់ម្ចាស់ម៉ាក។

## កថាភាគទី១៖ វិធានការតាមមាត់ច្រកព្រំដែន

ជាវិធានដែលអនុញ្ញាតឲ្យម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួចហើយ អាចធ្វើពាក្យបណ្តឹងទៅរដ្ឋបាលគយ

និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ ឬតុលាការឲ្យព្យួរទុកនូវការធ្វើបែបបទទំនិញណា ដែលសង្ស័យថាមានម៉ាកក្លែងក្លាយ ដោយគ្រាន់តែបង្ហាញនូវភស្តុតាងច្បាស់លាស់ថាគាត់ជាម្ចាស់នៃម៉ាក ដែលបានចុះបញ្ជី[៧១]។ វិធាននេះអនុញ្ញាតសម្រាប់តែម៉ាកដែលបានចុះបញ្ជីតែប៉ុណ្ណោះ នេះមានន័យថា ប្រសិនបើម៉ាកនោះមិនបានចុះបញ្ជីទេ គឺមិនអាចធ្វើពាក្យបណ្តឹងតាមវិធាននេះបានឡើយ។ ក្រៅពីម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយ ក៏នៅមានបុគ្គលមួយចំនួនទៀត ដែលអាចធ្វើបណ្តឹងបានផងដែរដូចជា៖ អ្នកដែលទទួលអាជ្ញាប័ណ្ណ ឬភ្នាក់ងារតំណាងស្របច្បាប់ ដោយបង្ហាញនូវភស្តុតាងច្បាស់លាស់ថា គាត់ជាម្ចាស់នៃម៉ាកដែលបានចុះបញ្ជី[៧២]។

## ១. សមត្ថកិច្ចតាមច្រកព្រំដែន

យោងតាមមាត្រា៣៥ នៃច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ លេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី ០៧ កុម្ភៈ ២០០២ បុគ្គលដែលជាអ្នកមានសមត្ថកិច្ចក្នុងការអនុវត្តន៍នូវវិធានការតាមមាត់ច្រកព្រំដែនរួមមាន៖ រដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ។ អាជ្ញាធរមានសមត្ថកិច្ចនៅទីនេះផ្អែកតាមមាត្រា ៣៦ នៃអនុក្រឹត្យស្តីពីការអនុវត្តន៍ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ៦៤ អនក្រ/បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០០៧ អាជ្ញាធរមានសមត្ថកិច្ចរួមមាន៖ អង្គភាពគយ និងរដ្ឋាករ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហ័រណេ អាហ័រណេ និងបង្ក្រាបការក្លែងបន្លំដែលហៅកាត់ថា កាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម និងនគរបាលមានសមត្ថកិច្ចនៃក្រសួងមហាផ្ទៃ។

## ២. ពាក្យបណ្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច

ពាក្យបណ្តឹងដែលបានលើកឡើងខាងលើនេះត្រូវធ្វើជាលាយល័ក្ខអក្សរ និងត្រូវភ្ជាប់មកជាមួយនូវ[៧៣] ៖

- វិញ្ញាបនប័ត្រចុះបញ្ជីម៉ាក
- សេចក្តីថ្លែងពីមូលហេតុនៃការប្តឹង និងជាពិសេសភស្តុតាងដំបូងដែលបង្ហាញថា ទំនិញនោះពិតជាពាក់ម៉ាកក្លែងក្លាយមែន
- ពាក្យរៀបរាប់ដ៏ល្អិតល្អន់អំពីទំនិញដែលម៉ាករបស់វាត្រូវបានប្រើប្រាស់ ព្រមទាំងគំរូនៃផលិតផលពិតប្រាកដផងប្រសិនបើមានសំណូមពរ

[៧១] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២, មាត្រា ៣៥

[៧២] អនុក្រឹតស្តីពីការអនុវត្តន៍ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ៦៤អនក្រ/បក, ២៩សីហា ២០០៧, មាត្រា៣៨, កថាខ័ណ្ឌទី១

[៧៣] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២, មាត្រា ៣៦

- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង និងតំណាងរបស់គេដែលត្រូវរៀបរាប់ឲ្យបានសព្វគ្រប់តាមការកំណត់
- លិខិតអនុញ្ញាតពីម្ចាស់ម៉ាកដែលបានចុះបញ្ជីប្រសិនបើពាក្យបណ្ដឹងនោះត្រូវបានដាក់ដោយតំណាងដែលទទួលសិទ្ធិ
- កម្រៃរដ្ឋបាលតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ពាក្យបណ្ដឹងនោះមានសុពលភាព ៦០ ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យបណ្ដឹង។ បើផុតសុពលភាពនេះ អ្នកដាក់ពាក្យត្រូវធ្វើពាក្យបណ្ដឹងឡើងវិញ បើសំណូមពរនៃការឃាត់ និងត្រួតពិនិត្យទំនិញនៅមាននៅឡើយ[៧៤]។

## ៣. ចំណាត់ការរបស់សមត្ថកិច្ចតាមច្រកព្រំដែន

### ក. ការជូនដំណឹងអំពីការព្យួរទុក

ក្នុងរយៈពេល ១០ ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលនូវពាក្យបណ្ដឹង (របស់ម្ចាស់ម៉ាកដែលបានចុះរួចហើយ) រដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងទៅអ្នកប្ដឹងថា ពាក្យបណ្ដឹងរបស់ខ្លួនត្រូវបានទទួលស្គាល់ថា ត្រឹមត្រូវ ឬបដិសេធ ឬមួយរក្សាទុកសម្រាប់ពិចារណានៅពេលក្រោយ[៧៥]។ រដ្ឋបាល និងរដ្ឋាករត្រូវជូនព័ត៌មានភ្លាមឲ្យម្ចាស់សិទ្ធិអំពីទីកន្លែង និងថ្ងៃដែលព្យួរទុកនូវការធ្វើបែបបទរបស់គយ និងរដ្ឋបាលគយ និងរដ្ឋាករ ក៏អាចស្នើឲ្យម្ចាស់សិទ្ធិផ្ដល់នូវព័ត៌មានទាំងឡាយណា ដែលអាចធ្វើជាជំនួយក្នុងការអនុវត្តន៍នូវអំណាចរបស់ខ្លួនផងដែរ[៧៦]។

### ខ. រយៈពេលនៃការព្យួរទុក

ក្នុងរយៈពេលយល់ព្រមតាមកម្មវត្ថុនៃពាក្យបណ្ដឹងខាងលើនេះ រដ្ឋបាលគយ និងរដ្ឋាករត្រូវព្យួរ ទុកនូវការធ្វើបែបបទទំនិញ ដែលមានទាក់ទងទៅនឹងពាក្យបណ្ដឹង។ ការព្យួរទុកនេះត្រូវនៅជាធរមានក្នុងរយៈពេលដំបូង និងក្នុងរយៈពេលដែលបានពន្យាមិនលើសពី ១០ ថ្ងៃនៃថ្ងៃធ្វើការ[៧៧]។ បន្ទាប់មករដ្ឋបាលគយ និងរដ្ឋាករ ត្រូវជូនព័ត៌មានភ្លាមទៅអ្នកនាំចូល និងអ្នកប្ដឹងអំពីការព្យួរទុកនូវការធ្វើបែបបទទំនិញ ដោយបញ្ជាក់ពីមូលហេតុនៃការព្យួរទុកនេះ ទន្ទឹមជាមួយគ្នានោះដែររដ្ឋបាលគយ និង រដ្ឋាករ ត្រូវបញ្ជាក់នូវឈ្មោះ និងអាសយដ្ឋាននៃអ្នកប្ដឹងដល់អ្នកនាំចូលផងដែរ។

[៧៤] ច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២, មាត្រា៣៦

[៧៥] ច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦,០៧ កុម្ភៈ ២០០២, មាត្រា៣៧

[៧៦] ច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២, មាត្រា៥៤

[77] ច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២, មាត្រា៣៩

ក្រោយពីទទួលបានដំណឹងអំពីការព្យួរទុកនូវការផ្ញើបែបបទទំនិញ អ្នកប្តឹងមានរយៈពេល១០ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីផ្តួចផ្តើមបន្តចំណាត់ការ ដែលឈានទៅដល់ការសម្រេចនូវអង្គសេចក្តីនៃករណីនេះ។ ក្នុងករណីសមស្របរយៈពេលនេះអាចត្រូវពន្យាពេល ១០ ថ្ងៃទៀតនៃថ្ងៃធ្វើការ[៧៨]។ កាលបើក្នុងរយៈពេលដូចដែលបានកំណត់នេះ រដ្ឋបាលគយ និងរដ្ឋាករបានទទួលនូវព័ត៌មានថា ចំណាត់ការដែលនាំដល់ការសម្រេចនូវអង្គសេចក្តី នៃករណីនេះមិនត្រូវបានផ្តួចផ្តើមឡើងដោយភាគីមួយទៀត ផ្សេងពីចុងចម្លើយ ឬថាអាជ្ញាធរដែលបានប្រគល់សិទ្ធិត្រឹមត្រូវ មិនអនុវត្តនូវវិធានការបណ្តោះអាសន្នដើម្បីពន្យាការដោះលែងទំនិញទេ ទំនិញនោះនឹងត្រូវដោះលែង តែក្នុងករណីដែលលក្ខ ខណ្ឌផ្សេងៗទៀត សម្រាប់ការនាំចូល ឬនាំចេញត្រូវបានគោរព។ ផ្ទុយទៅវិញប្រសិនបើចំណាត់ការដែលនាំឲ្យមានការសម្រេចនូវអង្គសេចក្តីនៃករណីត្រូវបានផ្តួចផ្តើមឡើង ការពិនិត្យឡើងវិញមានទាំងការធ្វើសវនាការផង ត្រូវបានរៀបចំឡើងតាមការស្នើសុំពីសំណាក់ចុងចម្លើយ ដើម្បីសម្រេចក្នុងរយៈពេលមួយសមស្របថាតើវិធាននេះត្រូវតម្កល់កែតម្រូវ ឬលុបចោល។

### ៣. សិទ្ធិត្រួតពិនិត្យ និងសិទ្ធិទទួលព័ត៌មាន

រដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀតអាចអនុញ្ញាតឲ្យម្ចាស់សិទ្ធិអ្នកនាំចូល ឬអ្នកនាំចេញពិនិត្យនូវទំនិញ ដែលបានព្យួរទុកតាមបែបបទគយ និងដកហូតនូវគំរូដើម្បីពិនិត្យសាកល្បង និងវិភាគក្នុងគោលបំណងបញ្ជាក់ឲ្យដឹងថា ទំនិញនោះពាក់ម៉ាកក្លែងក្លាយ ឬមិនក្លែងក្លាយ។ ក្រោយពេលដែលពិនិត្យទំនិញ ហើយដឹងថាជាទំនិញពាក់ម៉ាកក្លែងក្លាយ រដ្ឋបាលគយ និង រដ្ឋាករ អាចជូនព័ត៌មានទៅម្ចាស់សិទ្ធិនូវឈ្មោះ និងអាសយដ្ឋាននៃអ្នកនាំចេញ អ្នកនាំចូល អ្នកទទួល និងបរិមាណទំនិញ ដោយមិនធ្វើឲ្យប៉ះពាល់ដល់ការការពារនូវព័ត៌មានសម្ងាត់ រដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀត អាចផ្តល់ទៅឲ្យម្ចាស់សិទ្ធិនូវច្បាប់ចម្លងនូវឯកសារទំនិញទាំងនោះ ឬនូវព័ត៌មានដែលមាន ឬឯកសារដែលទាក់ទងនឹងការនាំចូល និងការនាំចេញនូវទំនិញប្រហាក់ប្រហែល ពីមុនដោយអ្នកនាំចូល ឬអ្នកនាំចេញដដែលនេះ តាមសំណូមពររបស់ម្ចាស់សិទ្ធិ[៧៩]។ អាជ្ញាធរសាធារណៈ និងមន្ត្រីទទួលបន្ទុកត្រូវបានលើកលែងពីការទទួលខុសត្រូវចំពោះវិធានការដោះស្រាយដោយសមស្រប នៅពេលដែលសកម្មភាពទាំងនោះត្រូវបានធ្វើ ឬមានបំណងនឹងធ្វើដោយស្មោះត្រង់[៨០]។

[៧៨] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២, មាត្រា៥០

[៧៩] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២, មាត្រា៥២

[៨០] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២, មាត្រា៥៥

### ឃ. សំណងចំពោះអ្នកនាំចូល និងចំពោះម្ចាស់ទំនិញ

អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ មានសិទ្ធិសម្រេចឲ្យអ្នកដែលប្តឹងសងទៅម្ចាស់អ្នកនាំចូល អ្នកនាំចេញ និងអ្នកទទួលទំនិញនូវបំណងសមស្របចំពោះការខូចខាតរបស់គេ ដែលបណ្តាលមកពីការឃាត់ទំនិញដោយមិនត្រឹមត្រូវ ឬការឃាត់ទុកទំនិញដែលបានដោះលែង។ ក្នុងករណី ភាគីណាមួយមិនយល់ព្រមតាមការកំណត់សេចក្តីសម្រេចនេះ ភាគីនោះមានសិទ្ធិប្តឹងទៅតុលាការ[៨១]។

### ៤. ការបំផ្លាញនូវទំនិញដែលពាក់ម៉ាកក្លែងក្លាយ

ដោយមានសេចក្តីសម្រេចពីតុលាការ រដ្ឋបាលគយ និងរដ្ឋាករ និងអាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិបំផ្លាញចោលនូវទំនិញដែលពាក់ម៉ាកក្លែងក្លាយនោះ។ រដ្ឋបាលគយ និងរដ្ឋាករ មិនត្រូវអនុញ្ញាតឱ្យធ្វើការណែនាំចេញបន្តនូវទំនិញដែលម៉ាកក្លែងក្លាយ ឬដាក់ទំនិញនេះឲ្យនៅក្រោមនីតិវិធីផ្សេងទៀតរបស់គយឡើយ[៨២]។

## កថាភាគទី២៖ ការដោះស្រាយវិវាទ

### ១. ការដាក់ពាក្យបណ្តឹង

ការដាក់ពាក្យបណ្តឹងអំពីការប្តឹងជំទាស់ទៅនឹងម៉ាក ដែលបានដាក់ពាក្យសុំចុះបញ្ជីប្តឹងជំទាស់ នឹងម៉ាកដែលបានចុះបញ្ជីរួចហើយ ប្តឹងមោឃភាពដល់ការចុះបញ្ជីម៉ាក និងប្តឹងពីបទរំលោភ បំពានពាណិជ្ជសញ្ញា គឺត្រូវធ្វើទៅតាមដំណាក់កាលនៃនីតិវិធី ហើយពាក្យបណ្តឹងនេះត្រូវតែធ្វើ ឡើងជាលាយលក្ខណ៍អក្សរ។

### ក. ប្តឹងជំទាស់នឹងម៉ាកដែលបានដាក់ពាក្យសុំចុះបញ្ជី

ក្នុងពេលដែលមានពាក្យស្នើសុំចុះបញ្ជីច្រើនទាក់ទងនឹងម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែលគ្នាហើយត្រូវបានប្រើចំពោះទំនិញ ឬសេវាដូច ឬប្រហាក់ប្រហែលគ្នា ហើយបានដាក់ពាក្យស្នើសុំចុះ បញ្ជីតាមពេលវេលាខុសគ្នា ឬក្នុងពេលជាមួយ ពេលនោះវិវាទមុខតែកើតមានឡើងដោយសារតែ ពួកគេកាន់ជំហរចង់ចុះបញ្ជីម៉ាកនោះដូចគ្នា។ ក្នុងករណីនេះ យោងតាមប្រការ ៤ នៃប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ការដោះស្រាយបណ្តឹង នៃវិវាទខាងលើ គឺជាសមត្ថកិច្ចរបស់ការិយាល័យចុះបញ្ជីម៉ាកពាណិជ្ជកម្ម។

### ខ. ប្តឹងជំទាស់នឹងម៉ាកដែលបានចុះបញ្ជីរួច

យោងតាមមាត្រា១០ ចំណុច (គ) នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួត ប្រជែងមិនស្មោះត្រង់ចែងថា "ក្នុងរង្វង់ ៩០ ថ្ងៃ បន្ទាប់បានចុះផ្សាយក្នុងប្រត្តិប័ត្រផ្លូវការ ហើយជនណាដែលមានការពាក់ព័ន្ធ

[៨១] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២, មាត្រា៤៦

[៨២] ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា, លេខ២១១ MOC, SM ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នំ ប្រកាស៣។

អាចជូនដំណឹងទៅមន្ត្រីកាន់កាប់បញ្ជីពីការជំទាស់របស់ខ្លួន ចំពោះការចុះបញ្ជីម៉ាកតាមបែបបទ ដែលបានកំណត់ ដោយឈរលើមូលដ្ឋាន នៃការមិនបានបំពេញ តាមលក្ខខណ្ឌនៃមាត្រា ២ ចំណុច (ក) មាត្រា ៤ និងមាត្រា ៥ និងបទបញ្ញាទាំងឡាយដែលពាក់ព័ន្ធ។" ក្នុងករណីនេះ យោងតាមមាត្រា ៤ នៃប្រកាសស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន កម្មសិទ្ធិបញ្ញា ការដោះស្រាយបណ្ដឹងនៃវិវាទខាងលើ គឺជាសមត្ថកិច្ចរបស់ការិយាល័យចុះបញ្ជីម៉ាកពាណិជ្ជកម្ម។

## គ. ប្ដឹងមោឃភាពដល់ការចុះបញ្ជីម៉ាក

យោងតាមមាត្រា ១៣ (ក) នៃច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ចែងថា "ជនណាដែលមានការពាក់ព័ន្ធអាចស្នើសុំមកក្រសួងពាណិជ្ជកម្ម ឲ្យផ្ដល់មោឃភាពដល់ការចុះបញ្ជីម៉ាកបាន"។ ពាក្យស្នើសុំនេះអាចធ្វើបាន ទោះផុតរយៈពេល ៩០ ថ្ងៃ បន្ទាប់ពីការបោះពុម្ពផ្សាយ ក្នុងព្រឹត្តិបត្រផ្លូវការក៏ដោយ[៨៣]។

## ឃ. ប្ដឹងពីបទរំលោភបំពានពាណិជ្ជ ឬសេវាសញ្ញា

យោងតាមមាត្រា ១១ ចំណុច (ខ) នៃច្បាប់ស្ដីពីម៉ាកចែងថា "ម្ចាស់ដើមនៃម៉ាកមានសិទ្ធិប្ដឹងទៅតុលាការ ប្រឆាំងនឹងជនណាម្នាក់ដែលប្រើប្រាស់ ដោយរំលោភនូវម៉ាករបស់ខ្លួនដោយគ្មាន ការយល់ព្រមពីម្ចាស់ដើម។ ម្ចាស់ដើមក៏មានសិទ្ធិក្នុងការប្ដឹងផងដែរចំពោះ តតិយជនដែលបានប្រើ ប្រាស់នូវសញ្ញាដែល ប្រហាក់ប្រហែលទៅនឹងម៉ាក ដែលខ្លួនបានចុះបញ្ជីរួចហើយនោះ ឬការប្រើប្រាស់ម៉ាក ដែលទាក់ទិនទៅនឹងទំនិញ និងសេវាដែលប្រហាក់ប្រហែលទៅនឹងទំនិញ ឬសេវានៃម៉ាក ដែលបានចុះបញ្ជីរួចហើយនោះដែលអាច បណ្ដាលឱ្យមានការភ័ន្តច្រឡំជាសាធារណៈ។" ក្នុងករណីនេះ សមត្ថកិច្ចដែលត្រូវដោះស្រាយនោះ គឺជាសមត្ថកិច្ចដោះស្រាយរបស់ការិយាល័យវិវាទ។

ដើម្បីចោទប្រកាន់ទង្វើមួយជាការរំលោភបំពានម៉ាក ត្រូវបង្ហាញឲ្យឃើញនូវចំណុចដូចជា៖

១. ចុងចោទបានចរាចរដោយចេតនា ឬបានប៉ុនប៉ងធ្វើចរាចរទំនិញ (សេវា ឬស្លាក សញ្ញាឯកសារ ឬសំបកវិចខ្ចប់សម្រាប់ទំនិញ ឬសេវា)។

២. ចុងចោទបានប្រើប្រាស់ម៉ាកក្លែងក្លាយនៅលើ ឬមានទំនាក់ទំនងទៅនឹងទំនិញ ឬ សេវាទាំងនោះ (ឬម៉ាកក្លែងក្លាយត្រូវបានបិទលើស្លាកសញ្ញា ឯកសារ ឬសំបកវិចខ្ចប់ទំនិញ ឬសេវា ទាំងនោះ) ដូចជា៖

- ម៉ាកក្លែងក្លាយជាម៉ាកមិនបរិសុទ្ធ ឬមិនត្រឹមត្រូវតាមច្បាប់។

[៨៣] អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ លេខ៦៤អនក្រ/បក, ២៩ សីហា ២០០៧, មាត្រា២៤, កថាខ័ណ្ឌទី១

- ម៉ាកក្លែងក្លាយជាម៉ាកមានលក្ខណៈដូចទៅនឹង ឬដែលមិនអាចញែកដាច់ពីម៉ាកបរិសុទ្ធ ដែលអ្នកផ្សេងទៀតបានធ្វើជាម្ចាស់ដើមរួចហើយ។
- ម៉ាកបរិសុទ្ធត្រូវបានចុះបញ្ជីក្នុងបញ្ជីដើម នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញាក្រសួងពាណិជ្ជកម្ម។
- ម៉ាកបរិសុទ្ធត្រូវបានកំពុងប្រើប្រាស់ ដោយម្ចាស់ម៉ាក ឬអ្នកទទួលអាជ្ញាប័ណ្ណនៃម៉ាក។
- ម៉ាកក្លែងក្លាយត្រូវបានប្រើប្រាស់ទៅលើ ឬមានទំនាក់ទំនងទៅនឹងទំនិញ ឬសេវារបស់ចុងចោទ ម៉ាកក្លែងក្លាយត្រូវបានបិទលើ ឬប្រើប្រាស់ក្នុងទំនាក់ទំនងទៅនឹងទំនិញ ឬសេវា ឬត្រូវបានបិទលើ ឬមាននៅក្នុងស្លាកសញ្ញា ឯកសារ ឬសំបកវិចខ្ចប់នៃប្រភេទ ឬចរិកលក្ខណៈណាមួយ។
- ម៉ាកក្លែងក្លាយត្រូវបានប្រើប្រាស់ ក្នុងទំនាក់ទំនងទៅនឹងប្រភេទនៃទំនិញ ឬសេវាសម្រាប់ម៉ាកដែលបានចុះបញ្ជីការពារ ឬស្លាកសញ្ញា ឯកសារ ឬសំបកវិចខ្ចប់ក្លែងក្លាយ ត្រូវបានរចនាឡើង ចរាចរ ឬបើមិនដូច្នេះទេមានចេតនាយកទៅប្រើប្រាស់លើ ឬក្នុងទំនាក់ទំនងទៅនឹង ទំនិញ ឬសេវា សម្រាប់ម៉ាកដែលបានចុះបញ្ជីរួច។
- ម៉ាកក្លែងក្លាយត្រូវបានប្រើប្រាស់ក្នុងរបៀបមួយ ដែលបណ្តាលឲ្យមានការភ័ន្តច្រឡំ បណ្តាលឲ្យមានកំហុស ឬក៏បំភ័ន្ត។

## ២. ការពិនិត្យពាក្យបណ្តឹងជំទាស់ក្រោយចុះបញ្ជី

ការពិនិត្យពាក្យបណ្តឹងជំទាស់ក្រោយពេលចុះបញ្ជីគឺ ជាការពិនិត្យទៅលើ៖ ឈ្មោះអ្នកប្តឹងជំទាស់ ឬភ្នាក់ងារតំណាង អាសយដ្ឋានទំនាក់ទំនង ជំពូកទំនិញ ម៉ាក កាលបរិច្ឆេទដាក់
ពាក្យ លេខដាក់ពាក្យ និងលេខចុះបញ្ជី។

## ៣. ការជូនដំណឹងអំពីពាក្យបណ្តឹង

បន្ទាប់ពីបានទទួលពាក្យបណ្តឹងពីម្ចាស់ដើមនៃម៉ាក ការិយាល័យវិវាទត្រូវជូនដំណឹងពីការ ប្តឹងនេះទៅគូវិវាទ។ ស្របពេលជាមួយគ្នានេះដែរ ការិយាល័យវិវាទ តំរូវឲ្យភាគីទាំងសងខាងផ្តល់ ឯកសារគាំទ្រ ដោយទុកឲ្យរយៈពេល ៤៥ ថ្ងៃ និងអាចពន្យាពេលថែម ៤៥ ថ្ងៃបន្ថែមទៀត[៨៤]។

## ៤. ការស្នើសុំបើកសវនាការ

មន្ត្រីកាន់កាប់បញ្ជីត្រូវចាត់ចែងឲ្យមានសវនាការ បើភាគីណាមួយ ឬភាគីទាំងពីរនៃជម្លោះ ស្នើសុំជាលាយលក្ខណ៍អក្សរឲ្យមានសវនាការ មុនពេលចេញសេចក្តីសម្រេចណាមួយ ពាក្យស្នើសុំ សវនាការនេះត្រូវធ្វើឡើងនៅមុនពេល ឬក្រោយពេល ០១ ខែ បន្ទាប់ពីថ្ងៃដាក់ពាក្យបណ្តឹង ឬឯកសារគាំទ្ររបស់ខ្លួនមកមន្ត្រីកាន់

[៨៤] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/ ០២០២/០០៦,០៧ កុម្ភៈ ២០០២,មាត្រា ១០

កាប់បញ្ជី។ ក្នុងករណីគ្មានពាក្យស្នើសុំសវនាការជាផ្លូវការតាម ការកំណត់ខាងលើ តាមឆន្ទានុសិទ្ធិដែលផ្តល់ដោយច្បាប់ មន្ត្រីកាន់កាប់បញ្ជីអាចចេញសេចក្តី សម្រេចរបស់ខ្លួនដោយគ្មានសវនាការ ឬបើយល់ឃើញថាចាំបាច់ត្រូវអញ្ជើញភាគីនៃជម្លោះមកធ្វើសវនាការ[៨៥]។ នៅពេលទទួលបានសំណើសុំធ្វើសវនាការ មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយ លក្ខណ៍អក្សរអំពីកាលបរិច្ឆេទនៃការបើសវនាការយ៉ាងតិច ០៧ ថ្ងៃនៃថ្ងៃធ្វើការ មុនពេលបើកសវនាការទៅបុគ្គល ដែលបានដាក់ពាក្យស្នើសុំធ្វើសវនាការ និងបុគ្គលដែលពាក់ព័ន្ធដទៃទៀត[៨៦]។

## ៥. អានុភាពនៃសេចក្តីសម្រេច

ក្រោយពីមានសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជី អំពីការផ្តល់មោឃភាពនៃការចុះបញ្ជី ឬការរក្សាទុកការចុះបញ្ជី ឬមួយសេចក្តីសម្រេចឲ្យកែតម្រូវម៉ាកដែលបានចុះបញ្ជី បើភាគីណាមួយ មិនយល់ព្រមនឹងសេចក្តីសម្រេចនោះ អាចប្តឹងតវ៉ាទៅក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា[៨៧] របស់ក្រសួងពាណិជ្ជកម្ម ឬប្តឹងទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីចេញសេចក្តីសម្រេច[៨៨]។ អនុលោមតាមមាត្រា៦២ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ភាគីមានផលប្រយោជន៍មានសិទ្ធិប្តឹងតវ៉ា អំពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា របស់ក្រសួងពាណិជ្ជកម្មទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីថ្ងៃចេញសេចក្តីសម្រេច[៨៩]។ អនុលោមតាមមាត្រា ៦២ ដដែលនេះ នៅពេលដែលតុលាការសម្រេចលើបណ្តឹងតវ៉ា តម្រូវឲ្យលុបម៉ាកចេញពីបញ្ជី ឬរក្សាទុក ឬកែតម្រូវម៉ាកមន្ត្រីកាន់កាប់បញ្ជីត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ[៩០]។

---

[៨៥] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ៦៤អនក្រ/បក, ២៩ សីហា ២០០៧ ,មាត្រា៣២, កថាខ័ណ្ឌទី១

[៨៦] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ៦៤អនក្រ/បក, ២៩ សីហា ២០០៧ ,មាត្រា៣២, កថាខ័ណ្ឌទី២

[៨៧] ក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ាមិនទាន់មាននៅឡើយទេនៅកម្ពុជា។ យោងតាមអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ៦៤អនក្រ/បក, ២៩ សីហា ២០០៧, មាត្រា២៤, កថាខ័ណ្ឌទី៥

[៨៨] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ៦៤អនក្រ/បក, ២៩ សីហា ២០០៧ ,មាត្រា២៤, កថាខ័ណ្ឌទី៧

[៨៩] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ៦៤អនក្រ/បក, ២៩ សីហា ២០០៧ ,មាត្រា២៤, កថាខ័ណ្ឌទី៨

[៩០] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ៦៤អនក្រ/បក, ២៩ សីហា ២០០៧ ,មាត្រា២៤, កថាខ័ណ្ឌទី១០

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការបកស្រាយ ទៅលើប្រធានបទខាងលើរួចមកនោះ យើងសង្កេតឃើញថា នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្មរបស់ព្រះរាជាណាចក្រកម្ពុជា ពិតជាបានចូលរួមចំណែកយ៉ាងខ្លាំងបំផុតក្នុងការអភិវឌ្ឍន៍ជាតិ ប្រកបដោយភាពរីកចម្រើន និងដំណើរការបានយ៉ាងល្អគួរឱ្យកត់សម្គាល់។ ជាក់ស្តែងនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការរៀបចំរចនាសម្ព័ន្ធ តួនាទី ភារកិច្ច ក្នុងការងារបម្រើសេវាកម្មកម្មសិទ្ធិបញ្ញានេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយក្នុងនេះដែរ នាយកដ្ឋានកម្មសិទ្ធិបញ្ញា បានបង្កើតឱ្យមានជាការិយាល័យមួយចំនួនដូចជា ការិយាល័យចុះបញ្ជីម៉ាកពាណិជ្ជកម្ម ការិយាល័យចុះបញ្ជីម៉ាកអន្តរជាតិ ការិយាល័យក្រោយចុះបញ្ជីម៉ាកពាណិជ្ជកម្ម ការិយាល័យម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងព័ត៌មានសម្ងាត់ពាណិជ្ជកម្ម ការិយាល័យវិវាទ ការិយាល័យសហប្រតិបត្តិការ និងកិច្ចការច្បាប់ ការិយាល័យអប់រំ និងចំណេះដឹងសាធារណៈ ការិយាល័យរដ្ឋបាលទូទៅ និងការិយាល័យស្វ័យប្រវត្តិ និងព័ត៌មានវិទ្យា។

ក្រសួងពាណិជ្ជកម្ម គឺជាស្ថាប័នទទួលខុសត្រូវ ការសម្របសម្រួលការងារកម្មសិទ្ធិបញ្ញា នឹងជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ដោយក្រសួងធ្វើការគ្រប់គ្រងលើម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព និងការការពារព័ត៌មានសម្ងាត់ពាណិជ្ជកម្ម។ ចំពោះក្រសួងឧស្សាហកម្ម និងសិប្បកម្មវិញ ជាស្ថាប័នដែលទទួលបន្ទុកលើកិច្ចការ ប្រកាសនីយបត្រតក្កកម្ម គំនូរឧស្សាហកម្ម និងម៉ូដែលមានអត្ថប្រយោជន៍ និងកិច្ចការពារប្រភេទរុក្ខជាតិថ្មី។ ចំណែកឯក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានចូលរួមចំណែកក្នុងវិស័យកម្មសិទ្ធិបញ្ញាលើសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។

ម្យ៉ាងវិញទៀត នាយកដ្ឋានកម្មសិទ្ធិបញ្ញា គឺជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា និងជាអ្នកទទួលបន្ទុកជាចំណុចកណ្តាល ក្នុងការសម្របសម្រួលកិច្ចសហប្រតិបត្តិការទ្វេភាគី ឬពហុភាគីលើវិស័យកម្មសិទ្ធិបញ្ញា ជាបណ្តាលប្រទេស និងអង្គការអន្តរជាតិផ្សេងៗទៀត។ ការសម្របសម្រួលឱ្យមានភាពល្អប្រសើរក្នុងការងារ ដែលទាក់ទងដល់កម្មសិទ្ធិបញ្ញារវាងក្រសួងពាក់ព័ន្ធ សហការជំរុញរៀបចំសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ធ្វើការផ្សព្វផ្សាយច្បាប់ ព្រមទាំងចំណេះដឹងផ្នែកកម្មសិទ្ធិបញ្ញា ដល់មហាជន មន្ត្រីអនុវត្តន៍ច្បាប់ សិស្ស និស្សិត តាមគ្រឹះស្ថានអប់រំ ព្រមទាំងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនានា និងស្ថាប័នតុលាការ ដើម្បីបញ្ឈប់ការរំលោភបំពានកម្មសិទ្ធិបញ្ញាតទៅទៀត។ ហើយនាយកដ្ឋានកម្មសិទ្ធិបញ្ញាមួយនេះជាអ្នកទទួល និងប្រើប្រាស់នៅជំនួយបច្ចេកទេសពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញាពីបណ្តាប្រទេសនានា និងអង្គ

ការអន្តរជាតិមួយចំនួនទៀត ក៏ដូចជាចូលរួមសិក្សាស្រាវជ្រាវកិច្ចព្រមព្រៀង និង អនុសញ្ញាអន្តរជាតិនានា ដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា និងធ្វើការពិចារណាអំពីប្រយោជន៍ជាតិ។

ថ្វីត្បិតតែនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មបានអនុវត្តន៍នូវតួនាទី ភារកិច្ច និងបានធ្វើការបែងចែកជាការិយាល័យមួយចំនួនក៏ដោយ ក៏ប៉ុន្តែនាយកដ្ឋានកម្មសិទ្ធិបញ្ញាមួយនេះ ហាក់បីដូចជានៅមានចំណុចខ្វះខាតមួយចំនួនផងដែរ។ ជាក់ស្តែង ការិយាល័យនីមួយៗ តែងតែមានបញ្ហាទាក់ទងទៅនឹងហិរញ្ញវត្ថុ ការងារត្រួតស៊ីគ្នា និងការខ្វះមន្ត្រីជំនាញ។ ចំណែកប្រជាពលរដ្ឋវិញ ក៏មានការលំបាកក្នុងការទទួលបាននូវកញ្ចប់សេវាកម្មសិទ្ធិបញ្ញារួមមួយ ជាពិសេស ប្រជាជននៅមានការខ្វះខាតផ្នែកចំណេះដឹងខាងកម្មសិទ្ធិបញ្ញា ដែលជាហេតុនាំឱ្យការរំលោភបំពានកម្មសិទ្ធិបញ្ញា។

ដើម្បីឱ្យមានភាពប្រសើរឡើងនូវចំណុចខ្វះខាតទាំងនេះ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ក៏ដូចជាក្រសួងពាណិជ្ជកម្ម ត្រូវការកែលម្អផ្នែករដ្ឋបាលកម្មសិទ្ធិបញ្ញា រចនាសម្ព័ន្ធឱ្យមានភាពច្បាស់លាស់ និងឱ្យមានប្រសិទ្ធភាពកាន់តែល្អកុំឱ្យចាញ់បណ្តាប្រទេសជឿនលឿនមួយចំនួនទៀត។

# អនុសាសន៍

យោងតាមការស្រាវជ្រាវ អង្កេតពិនិត្យទៅលើសកម្មភាពផ្នែកកម្មសិទ្ធិបញ្ញា ជាពិសេសនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ជាសេនាធិការឱ្យរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា យើងខ្ញុំយល់ឃើញថា នាពេលកន្លងមក និងពេលអនាគតផ្នែកកម្មសិទ្ធិបញ្ញាស្ថិតនៅក្នុងសមាជិកអាស៊ាន ដែលមានយន្តការបង្កើតអាជ្ញាធរជាតិគ្រប់គ្រង លើផ្នែកកម្មសិទ្ធិបញ្ញាមានការស៊ីសង្វាក់ជាមួយសេដ្ឋកិច្ចទីផ្សារអាស៊ាន ស្របទៅតាមចរន្តអន្តរជាតិចង់បានឱ្យមានរដ្ឋបាលកម្មសិទ្ធិបញ្ញាតែមួយ។ រាជរដ្ឋាភិបាលគួរពង្រឹងអាជ្ញាធរជាតិកម្មសិទ្ធិបញ្ញាលើយន្តការនេះតែងតែមានគុណវិបត្តិតិចតួច ប៉ុន្តែការអនុវត្តលើយន្តការកម្មសិទ្ធិបញ្ញានេះ មានចំណុចល្អជាច្រើន និងមានការទំនាក់ទំនងល្អចំពោះព្រះរាជាណាចក្រកម្ពុជា។

នាយកដ្ឋានកម្មសិទ្ធិបញ្ញា មិនត្រឹមតែជំនួយការ ឬជាសេនាធិការឱ្យក្រសួងពាណិជ្ជកម្មប៉ុណ្ណោះទេ ផ្នែកកម្មសិទ្ធិបញ្ញាមានការទាក់ទង និងគ្នារហូតដល់ថ្នាក់ជាតិ ជាធាតុផ្សំមួយដ៏រឹងមាំ ដែលប្រមូលផ្តុំនូវអ្នកជំនាញខាងកម្មសិទ្ធិបញ្ញា អនុញ្ញាតឱ្យមកធ្វើការរួមគ្នាប៉ុណ្ណោះទេ ប៉ុន្តែផ្នែកកម្មសិទ្ធិបញ្ញានេះបានជួយផ្តល់ នូវសេវាកម្មសិទ្ធិបញ្ញាជូនដល់អាជីវករបានល្អប្រសើរ មានភាពរលូន និងរហ័ស ដែលជាកត្តាទាក់ទាញអ្នកវិនិយោគទុនបានកាន់តែច្រើន ដើម្បីមកបណ្តាក់ទុននៅព្រះរាជាណាចក្រកម្ពុជាថែមទៀត។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានឹងទទួលបានប្រាក់ចំណូលជាបន្តបន្ទាប់លើវិស័យកម្មសិទ្ធិបញ្ញា និងអាចធ្វើឱ្យរដ្ឋមានលទ្ធភាពបង្កើតប្រាក់បៀវត្សដល់មន្ត្រីរាជការលើវិស័យកម្មសិទ្ធិបញ្ញា ហើយថែមទាំងជួយលុបបំបាត់នូវអំពើពុករលួយផងដែរ។ ជាពិសេសការបង្កើតឱ្យមានកម្មសិទ្ធិបញ្ញានេះ ជាសកម្មភាពមួយដែលបានបង្ហាញ ពីការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងដំណើរការកំណែទម្រង់ទៅលើស្ថាប័នរដ្ឋបាលថ្នាក់ជាតិ ដើម្បីឱ្យសមស្របតាមគោលនយោបាយចតុកោណ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន។

នៅចុះបញ្ចប់នេះ អាត្មាភាពខ្ញុំបាទសូមឱ្យរាជរដ្ឋាភិបាលគួរតែបង្កើតជាអាជ្ញាធរជាតិកម្មសិទ្ធិបញ្ញា ដែលជាសញ្ញាវិជ្ជមានល្អបំផុត និងបង្ហាញពីសកម្មភាពល្អ មានប្រសិទ្ធភាពខ្ពស់លើផ្នែកកម្មសិទ្ធិបញ្ញានៅព្រះរាជាណាចក្រកម្ពុជា បានឆ្លុះបញ្ចាំងឬការបង្ហាញឱ្យពិភពលោក បានស្គាល់កាន់តែច្បាស់ពីសក្តានុពលរបស់ប្រទេសកម្ពុជា ដែលព្រះរាជាណាចក្រអច្ឆរិយៈ និងជាប្រទេសដែលមាននីតិរដ្ឋនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ម្យ៉ាងទៀត នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវធ្វើយ៉ាងណាឱ្យមានតុល្យភាពចំពោះវិស័យកម្មសិទ្ធិបញ្ញា និងធ្វើការទប់ស្កាត់នូវសកម្មភាពផ្សេងៗដែលទាក់ទងទៅការរំលោភបំពានលើកម្មសិទ្ធិបញ្ញា ហើយធ្វើយ៉ាងណាឱ្យមានភាពរីកចម្រើនទៅលើវិស័យមួយនេះផងដែរ។

# ឯកសារពិគ្រោះ

## ក. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត


១. ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៦ ធ្នូ ២០០១

២. ព្រះរាជក្រមស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម, លេខ នស/រកម/១២១៣/០១៨, ០៩ ធ្នូ ២០១៣

៣. ព្រះរាជក្រមស្តីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, លេខ នស/រកម/០១៩៦/០២, ២៤ មករា ១៩៩៦

៤. អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម, លេខ ១៣១ អនក្រ/បក, ១៩ មីនា ២០១៥

៥. អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, លេខ ២៤ អនក្រ/បក, ១៩ មីនា ២០០៧

៦. អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា, លេខ ១៥២ អនក្រ/បក, ១៨ កញ្ញា ២០០៨

៧. ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា, លេខ ២០៦/ប្រក, ១៨ កក្កដា ២០១៤

៨. ប្រកាសស្តីពីការកែសម្រួល និងបង្កើតការិយាល័យបន្ថែមចំណុះឱ្យនាយកដ្ឋានកម្មសិទ្ធិបញ្ញា, លេខ ១៧២ ពណបល/ប្រក, ១៦ ឧសភា ២០១៦

៩. ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម, លេខ ៤៥១ ប្រក, ២៨ ឧសភា ២០១៤

១០. ប្រកាសស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធនាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, លេខ ១៦៨ ប្រក, ០៦ សីហា ២០០៧

១១. សេចក្តីព្រាងស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងផ្នែកទាំងបីនៃកម្មសិទ្ធិបញ្ញា, លេខ ១៦ សសរ, ២២ កុម្ភៈ ១៩៩៩


## ខ. សៀវភៅ


១២. អង្គការកម្មសិទ្ធិបញ្ញាពិភពលោក, យល់ដឹងពីកម្មសិទ្ធិបញ្ញា និងសិទ្ធិអ្នកនិពន្ធ, នាយកដ្ឋានសិទ្ធិអ្នក និពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៃក្រសួងពាណិជ្ជកម្ម និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

១៣. នាយកដ្ឋាននីតិកម្ម នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ,២០១២, កម្រងបទដ្ឋាន គតិយុត្តក្នុងវិស័យ វប្បធម៌ និងវិចិត្រសិល្បៈ, ភ្នំពេញ


## គ. របាយការណ៍ វគ្គបណ្តុះបណ្តាល


១៤. ក្រសួងពាណិជ្ជ, សេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០១៣, (២៥ មេសា ២០១៤)

១៥. ក្រសួងពាណិជ្ជ, សេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០១៨-២០១៩

១៦. ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, របាយការណ៍សកម្មភាពប្រចាំឆ្នាំចាប់ ពីខែមករា ដល់ ខែធ្នូ ឆ្នាំ ២០១៣

១៧. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, របាយការណ៍ស្តីពី លទ្ធផលការងារវប្បធម៌ និងវិចិត្រសិល្បៈប្រចាំឆ្នាំ ២០១៥, (១២-០១-២០១៦)

១៨. ពិន សុវិចិត្រ, វគ្គបណ្តុះបណ្តាលសម្រាប់ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក

១៩. ង៉ែត វិបុល, "ការត្រួតពិនិត្យលើខ្លឹមសារនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម និងបញ្ហាប្រឈម", (បទបង្ហាញនៅក្នុងសិក្ខាសាលាកម្មសិទ្ធិបញ្ញា, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២៤ មេសា ២០០៨)។

២០. អង្គការកម្មសិទ្ធិបញ្ញាពិភពលោក, ២០១២, បណ្តុះបណ្តាលស្តីពីការអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញា, ០៥ ដល់ទី១៦ វិច្ឆិកា

**ឃ. គេហទំព័រ**

២១. http://www.cambodiaip.gov.kh/ (ថតចម្លងថ្ងៃទី២០ ខែមីនា ២០១៩)

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ អង្គការលេខរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា

ឧបសម្ព័ន្ធទី២៖ អង្គការលេខរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម

ឧបសម្ព័ន្ធទី៣៖ អង្គការលេខរបស់នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

ឧបសម្ព័ន្ធទី៤៖ ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

ឧបសម្ព័ន្ធទី៥៖ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា

ឧបសម្ព័ន្ធទី៦៖ ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា

ឧបសម្ព័ន្ធទី៧៖ បញ្ជីលំដាប់អក្សរក្រមរបស់ការិយាល័យកម្មសិទ្ធិបញ្ញា